

# ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ២០០៩: ស្ត្រីនៅក្នុងពន្ធនាគារ

របាយការណ៍លីកាដូ
ខែមិនា ឆ្នាំ២០០៩


លីកាដូ
LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

Cambodian League for the
Promotion and Defense of Human Rights

# ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ២០០៨

# ស្ត្រីនៅក្នុងពន្ធនាគារ

---

របាយការណ៍លីកាដូ

ខែមីនា ឆ្នាំ២០០៩

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ :**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែក ច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវិជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវិជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណៈជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេត ដោយលីកាដូត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរក ព័ត៌មានវិភាគ និងផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្ស)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១   ទូរសារ: (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦
អ៊ីម៉ែល: contact@licadho-cambodia.org   គេហទំព័រ: http://www.licadho-cambodia.org/

# មាតិកា

**១. សេចក្តីផ្តើម** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១

វិធីសាស្ត្រ: ការឃ្លាំមើលស្ថានភាពក្នុងពន្ធនាគារ --------------------------------- ២

វិធីសាស្ត្រ: ការឃ្លាំមើលបញ្ហាសុខភាពក្នុងពន្ធនាគារ ------------------------------៥

**២. ស្ត្រីក្នុងពន្ធនាគារ** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~៨

ចំនួនអ្នកទោស --------------------------------------------------- ១៩

លក្ខណៈពន្ធនាគារ ------------------------------------------------២២

**៣. សុខភាពក្នុងពន្ធនាគារ** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ២៧

ការស្លាប់នៅក្នុងពន្ធនាគារ----------------------------------------------- ២៨

អំពើទារុណកម្មនៅក្នុងពន្ធនាគារ ----------------------------------------- ៣០

**៤. កុមារនៅក្នុងពន្ធនាគារ** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៤

**៥. អនុសាសន៍** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៧

□□□

# ១. សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ១៩៩៧មក អង្គការលីកាដូបានចេញផ្សាយរបាយការណ៍ជាច្រើនស្តីពីស្ថានភាពពន្ធនាគារកម្ពុជា ដោយបានលើកឡើងពីកង្វល់ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សដែលគួរឱ្យព្រួយបារម្ភជាច្រើន និងលើកជាអនុសាសន៍មួយចំនួន ដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យមួយ អង្គការលីកាដូ មានគោលបំណងសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ឃ្លាំមើលស្ថានភាពពន្ធនាគារកម្ពុជា និងសិទ្ធិរបស់អ្នកទោស។
- ផ្សព្វផ្សាយព័ត៌មានដែលមានគុណភាព និងឥតលំអៀង។
- ធ្វើការបញ្ចុះបញ្ចូល ដើម្បីឱ្យមានការកែទម្រង់ប្រកបដោយភាពវិជ្ជមាន។



របាយការណ៍របស់អង្គការលីកាដូ ស្តីពីស្ថានភាពពន្ធនាគារពីរកន្លងទៅ បានអធិប្បាយអំពីស្ថានភាពរស់នៅរបស់អ្នកទោសជាបុរស[១] និងស្ត្រីជាម្តាយរស់នៅក្នុងពន្ធនាគារជាមួយកូន[២]។ ចំពោះរបាយការណ៍នេះវិញ មានគោលបំណងអធិប្បាយអំពីអ្នកទោសជាស្ត្រី និងបទពិសោធន៍ដែលពួកគាត់បានជួបប្រទះនៅក្នុងពន្ធនាគារ។ របាយការណ៍នេះ ក៏លើកយកមកនិយាយអំពីប្រភេទបទល្មើសដែលស្ត្រីទាំងនោះបានប្រព្រឹត្ត និងស្ថានភាពរស់នៅរបស់ពួកគាត់ក្នុងពន្ធនាគារ។ ករណីសិក្សានីមួយៗ ត្រូវបានដកស្រង់ចេញពីរឿងរ៉ាវជីវិតពិតរបស់អ្នកទោស ហើយឈ្មោះ និងព័ត៌មានលំអិតមួយចំនួនត្រូវបានផ្លាស់ប្តូរ ក្នុងគោលបំណងដើម្បីការពារអត្តសញ្ញាណរបស់អ្នកទោស។ របាយការណ៍នេះក៏ផ្តល់ព័ត៌មានបន្ថែម ទាក់ទងនឹងស្ថិតិស្តីអំពីបញ្ហាពាក់ព័ន្ធមួយចំនួន ដែលប្រមូលបាននៅក្នុងឆ្នាំ២០០៧ និង២០០៨ ផងដែរ។

របាយការណ៍នេះ ត្រូវគេរំពឹងថា នឹងត្រូវបានយកទៅប្រើប្រាស់ដោយរដ្ឋាភិបាល និងមន្ត្រីពន្ធនាគារ អ្នកតស៊ូមតិសិទ្ធិមនុស្ស អ្នកស្រាវជ្រាវ សារព័ត៌មាន ម្ចាស់ជំនួយ និងអ្នកជំនាញផ្នែកច្បាប់ ជាឯកសារយោងមួយ ដើម្បីកំណត់នូវបញ្ហាដែលកើតមាននៅក្នុងពន្ធនាគារ និងដើម្បីធ្វើឱ្យស្ថានភាពពន្ធនាគារប្រសើរឡើង និងលើកកំពស់សិទ្ធិរបស់អ្នកទោស។

---

[១] របាយការណ៍លីកាដូ ឆ្នាំ២០០៧ *"ស្ថានភាពពន្ធនាគារនៅកម្ពុជាឆ្នាំ២០០៥ និង២០០៦ៈ ថ្ងៃមួយក្នុងជីវភាពរស់នៅជា..."* http://www.licadho-cambodia.org/reports.php?perm=104

[២] របាយការណ៍លីកាដូ ឆ្នាំ២០០៨ *"ស្ថានភាពពន្ធនាគារនៅកម្ពុជាឆ្នាំ២០០៧ៈ រឿងនិទាន ម្តាយ និងកូនស្រីម្នាក់"* http://www.licadho-cambodia.org/reports.php?perm=116

## វិធីសាស្ត្រ: ការឃ្លាំមើលស្ថានភាពក្នុងពន្ធនាគារ

អ្នកស្រាវជ្រាវពន្ធនាគារ និងបុគ្គលិកពេទ្យរបស់អង្គការ លីកាដូ បានចងក្រងនូវករណីសិក្សា និងព័ត៌មានស្តីអំពីស្ថិតិដែលមានក្នុងរបាយការណ៍នេះ។ អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការ លីកាដូ ប្រចាំទីក្រុងភ្នំពេញ បានចុះស្រាវជ្រាវក្នុងពន្ធនាគារនីមួយក្នុងក្រុងភ្នំពេញ ១ ដង ក្នុងសប្តាហ៍ (មណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ ពន្ធនាគារតាខ្មៅ និងពន្ធនាគារប៉េហ្ស៊ី) ហើយអ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការ លីកាដូ នៅតាមខេត្តចុះស្រាវជ្រាវក្នុងពន្ធនាគារខេត្តនីមួយៗម្តងក្នុងមួយសប្តាហ៍[៣] ។

រៀងរាល់ការចុះទៅសម្ភាសន៍ត្រូវប្រើរយៈពេលយ៉ាងច្រើនចាប់ពី ២-៣ ម៉ោង អ្នកស្រាវជ្រាវពន្ធនាគារបានសម្ភាសន៍អ្នកទោស ២-៤ នាក់ ដោយប្រើកម្រងសំណួរជាបទដ្ឋានមួយ ដែលចងក្រងស្តីពីព័ត៌មានលំអិតអំពីការប្រព្រឹត្ត ស្ថានភាពរស់នៅ ពាក្យបណ្តឹង ព័ត៌មានទាក់ទងខាងផ្លូវច្បាប់ (ការចាប់ខ្លួន ការឃុំខ្លួន សវនាការ ការផ្តន្ទាទោស និងមេធាវី) និងព័ត៌មានសំខាន់ផ្សេងៗទៀតរបស់អ្នកទោស។ ជាធម្មតា ការសម្ភាសន៍ត្រូវបានធ្វើឡើងនៅក្នុងទីកន្លែងសម្ភាសន៍មួយ ដែលអាចជាបន្ទប់មួយ ឬទីធ្លាខាងក្រៅបន្ទប់ឃុំឃាំង ដែលមានតុមួយ កៅអីមួយ នឹងមានវត្តមានមន្ត្រីពន្ធនាគារម្នាក់ផងដែរ។ ដោយសារតែមានវត្តមានមន្ត្រីពន្ធនាគារ ឬអ្នកទោសដទៃទៀតនៅទីនោះ ហេតុដូច្នេះ ការសម្ងាត់មួយចំនួនមិនអាចធានាបានឡើយ ទោះជាអ្នកស្រាវជ្រាវពន្ធនាគារ ស្វែងរកកន្លែងដែលអាចសម្ភាសន៍ជាលក្ខណៈបុគ្គលក៏ដោយ។ រាល់ការចុះទៅសម្ភាសន៍ទាំងអស់ត្រូវតែរៀបចំទុកជាមុន រីឯអ្នកទោសទាំងអស់ត្រូវបានជ្រើសរើសពីបញ្ជីឈ្មោះអ្នកទោស ដែលអាចរកបាននៅការិយាល័យរដ្ឋបាលនៃពន្ធនាគារនិមួយៗ។

---

[៣] ដោយទាក់ទងទៅនឹងបញ្ហាថវិការ និងសំភារៈ អ្នកស៊ើបអង្កេត លីកាដូ ចុះទៅស្រាវជ្រាវ និងសម្ភាសន៍ទណ្ឌិតក្នុងពន្ធនាគារដែលនៅក្បែរការិយាល័យភ្នំពេញ និងការិយាល័យតាមបណ្តាខេត្តទាំង ១២ របស់ខ្លួនតែប៉ុណ្ណោះ។ ពន្ធនាគារទាំងនោះរួមមាន នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) មណ្ឌលអប់រំកែប្រែទី១ "ម-១" (អតីតគុក តេ ៣) មណ្ឌលអប់រំកែប្រែទី២ "ម-២" (សម្រាប់ឃុំឃាំង ទណ្ឌិតស្ត្រី និងអនីតិជន) មណ្ឌលអប់រំកែប្រែទី ៣ "ម-៣" (អតីតគុកត្រពាំងផ្លុង ឬ តេ ៥) ពន្ធនាគារយោធាទួលស្លែង តាខ្មៅ ក្រុងកំពង់សោម កំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង និងកោះកុង។ អ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ មិនបានបន្តឃ្លាំមើលនៅពន្ធនាគារខេត្តព្រៃវែង និងតាកែវទៀតទេ ទោះជាពន្ធនាគារទាំងនោះនៅជិតការិយាល័យលីកាដូក៏ដោយ។ ក្នុងខេត្តដែលគ្មានកាយាល័យ លីកាដូ ដូចជាខេត្តមណ្ឌលគីរី រតនគីរី ក្រចេះ ស្ទឹងត្រែង តាកែវ និងព្រៃវែង លីកាដូមិនចុះទៅឃ្លាំមើលទេ។ សមាគមន៍សិទ្ធិមនុស្សកម្ពុជា និងអភិវឌ្ឍន៍ "អាដហុក" ជួបប្រជុំជាមួយប្រធានពន្ធនាគារដែលគ្មានការិយាល័យ លីកាដូ ហើយបានធ្វើការអធិការកិច្ច ក្នុងពេលកំណត់មួយ ទោះជាមិនមានអ្នកស្រាវជ្រាវពន្ធនាគារ និងក្រុមគ្រូពេទ្យជាអចិន្ត្រៃយ៍ក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យពេទ្យ លីកាដូ បានចុះទៅពិនិត្យ និងព្យាបាលក្នុងពន្ធនាគារមួយចំនួនដូចជា តាខ្មៅ កំពង់ចាម តាកែវ កំពង់ចាម ស្វាយរៀង ព្រៃវែង ប៉េហ្ស៊ី ទួលស្លែង កោះកុង ពោធិ៍សាត់ ក្រុងកំពង់សោម បាត់ដំបង និងកំពង់ធំ។ ចំណែកឯពន្ធនាគារមួយចំនួនទៀតត្រូវចុះទៅពិនិត្យ និងព្យាបាលដោយអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដូចជា "កម្មវិធីតាមដានពន្ធនាគារ" ជាដើម។

## ទីតាំងពន្ធនាគារ ដែលត្រូវបានឃ្លាំមើលដោយអង្គការលីកាដូ




★ ពន្ធនាគារដែលត្រូវបានឃ្លាំមើលដោយអង្គការលីកាដូ

▲ ពន្ធនាគារដែលមិនត្រូវបានឃ្លាំមើលដោយអង្គការលីកាដូ

■ ខេត្តដែលមានការិយាល័យរបស់អង្គការលីកាដូ

■ ខេត្តដែលគ្មានការិយាល័យរបស់អង្គការលីកាដូ

ចំនួននៃការសម្ភាស៍អ្នកទោស ដែលធ្វើឡើងដោយអ្នកស្រាវជ្រាវពន្ធនាគាររបស់ លីកាដូ មានបង្ហាញដូចខាងក្រោម៖

**ចំនួននៃការសម្ភាសន៍អ្នកទោសក្នុងពន្ធនាគារនីមួយៗ ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយ លីកាដូ ពីឆ្នាំ ២០០៧-២០០៨**

| ពន្ធនាគារ | ២០០៧ | | ២០០៨ | |
|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី |
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ៥៤ | ២ | ៣៨ | ៩ |
| មណ្ឌលអប់រំកែប្រែទី១ (ម-១) | ៩០ | ០ | ៤០ | ០ |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ៥២ | ៤៨ | ៣៣ | ៤៥ |
| មណ្ឌលអប់រំកែប្រែទី៣ (ម-៣) | ២០៩ | ០ | ១៣៦ | ០ |
| ទួលស្លែង | ០ | ០ | ០ | ០ |
| តាខ្មៅ | ៩៣ | ១១ | ៦០ | ២០ |
| ព្រះសីហនុ | ១០៦ | ៣ | ៦៤ | ៤ |
| ខេត្តកំពង់ស្ពឺ | ៥៨ | ៥ | ៤៩ | ៤ |
| ខេត្តកំពត | ១២៩ | ៥ | ២០២ | ៧ |
| ខេត្តកំពង់ឆ្នាំង | ១៦៩ | ១០ | ១៣៧ | ៥ |
| ខេត្តកំពង់ចាម | ១៨០ | ២៦ | ៧៥ | ៥ |
| ខេត្តកំពង់ធំ | ២៨០ | ១២ | ២៩០ | ១៧ |
| ខេត្តកោះកុង | ៨១ | ៩ | ៧០ | ៧ |
| ខេត្តពោធិ៍សាត់ | ២១៧ | ៦ | ១៥១ | ៨ |
| ខេត្តបាត់ដំបង | ៧៦ | ៥ | ៥៨ | ៧ |
| ខេត្តបន្ទាយមានជ័យ | ១១០ | ១១ | ៤៨ | ២ |
| ខេត្តសៀមរាប | ២៧៥ | ៤៤ | ២០៤ | ២៣ |
| ខេត្តស្វាយរៀង | ១៦៩ | ១១ | ១២៧ | ១១ |
| **សរុប** | **២៣៤៨** | **២០៨** | **១៨០៩** | **១៧៤** |

## វិធីសាស្ត្រ: ការឃ្លាំមើលបញ្ហាសុខភាពក្នុងពន្ធនាគារ

អង្គការលីកាដូមានជំនឿយ៉ាងមុតមាំថា ជនគ្រប់រូបរួមទាំងអ្នកជាប់ឃុំឃាំងផង នឹងទទួលបានសិទ្ធិថែទាំសុខភាពជាមូលដ្ឋាន។ ក្រោយពេលបង្កើតការិយាល័យពេទ្យនៅក្នុងឆ្នាំ១៩៩៣ អង្គការលីកាដូបានចាប់ផ្តើមធ្វើការជាមួយពន្ធនាគារចំនួនពីរនៅទីក្រុងភ្នំពេញ។ ដោយស្របពេលគ្នានោះ ពន្ធនាគារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានជួបប្រទះនូវបញ្ហាសុខភាពមួយចំនួនដែរ។

រយៈជាងមួយទសវត្សកន្លងទៅ ការិយាល័យពេទ្យនៃអង្គការលីកាដូមានការងារមមាញឹកជាងគេនៅក្នុងអង្គការ ដែលត្រូវចុះទៅពន្ធនាគារទាំង ១២ នៅក្នុងប្រទេសទាំងមូលជារៀងរាល់ខែ[៤] ដែលមានចំនួនអ្នកទោសសរុប ២០០០ នាក់។ នៅពេលចុះទៅពិនិត្យម្តងៗ ត្រូវចំណាយពេល ១ ថ្ងៃ ប៉ុន្តែសំរាប់ពន្ធនាគារណាដែលមានទំហំធំ ត្រូវចំណាយពេលចាប់ពី ២ ឬ ៣ ថ្ងៃ។ ជារៀងរាល់សប្តាហ៍ ការិយាល័យពេទ្យនឹងរៀបចំការចុះសួរសុខទុក្ខ ៣ ឬ ៤ ពន្ធនាគារ។ ក្នុងការចុះទៅជួបត្រូវបានរៀបចំទុករួចជាស្រេចរវាងពន្ធនាគារ អ្នកស្រាវជ្រាវ មន្ត្រីពន្ធនាគារ និងក្រុមពេទ្យ។

ក្រុមគ្រូពេទ្យដែលចុះសួរសុខទុក្ខមានចំនួន ២ នាក់ និង សហការី ១ នាក់ ដោយយកទៅជាមួយដោយថ្នាំពេទ្យ សំភារៈពេទ្យ ដូចជាបង់រុំរបួស និងអាហារជាដើម។ គោលបំណងនៃការចុះសួរសុខទុក្ខ គឺដើម្បីផ្តល់ការពិនិត្យសុខភាពទូទៅដល់អ្នកទោស។ ការត្រួតពិនិត្យសុខភាពមានផ្តល់ដូចជា វេជ្ជបញ្ជានៃការព្យាបាល (ដែលអនុញ្ញាតឱ្យប្រើប្រាស់ដោយមន្ត្រីសុខភាពនៅពន្ធនាគារ) ក្នុងករណីអ្នកទោសមានជំងឺធ្ងន់ធ្ងរ ត្រូវបញ្ជូនទៅព្យាបាលជាបន្ទាន់ ឬបញ្ជូនទៅកាន់មន្ទីរពេទ្យ (ការបញ្ជូនទៅត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នក្រោមការត្រួតពិនិត្យរបស់ប្រធានពន្ធនាគារ ចំណែកក្រុមពេទ្យគ្រាន់តែធ្វើជាសំណើរតែប៉ុណ្ណោះ)។ ក្រុមពេទ្យក៏ឆ្លៀតឱកាសធ្វើការតាមដាន នឹងចែកថ្នាំឱ្យអ្នកទោស ហើយការធ្វើនេះ មិនទាមទារឱ្យមានការស៊ីសំណូកឡើយ។



[៤] ពន្ធនាគារតាខ្មៅ, តាកែវ, ព្រៃវែង, ស្វាយរៀង, កំពង់ធំ, កំពង់ចាម, កោះកុង, កំពង់ស្ពឺ, ព្រះសីហនុ, ពោធិ៍សាត់, បាត់ដំបង និងពន្ធនាគារពីរទៀតនៅក្រុងភ្នំពេញ-នគរបាលយុត្តិធម៌ និងទួលស្លែង ។

ការត្រួតពិនិត្យសុខភាពជាធម្មតាធ្វើឡើងនៅក្នុងបន្ទប់ឃុំឃាំង។ ទោះជាយ៉ាងណាក្តី ពេលខ្លះការពិនិត្យសុខភាពអាចធ្វើនៅខាងក្រៅបន្ទប់ឃុំឃាំងដែរ។ នៅរៀងរាល់ពេលចុះទៅពិនិត្យ ក្រុមគ្រូពេទ្យអាចជួបអ្នកទោសប្រហែល ២០០ នាក់។ បន្ថែមពីលើកាលវិភាគប្រចាំខែ ក្រុមពេទ្យអាចព្យាបាលករណីពិសេសដែលចាំបាច់ និងបន្ទាន់ ដែលអនុញ្ញាតឱ្យក្រុមពេទ្យធ្វើការតាមដានសុខភាពដល់អ្នកទោសណាដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរ ឬក៏ស្ថានភាពបន្ទាន់ណាមួយ។

## ទីតាំងពន្ធនាគារដែលចុះពិនិត្យដោយក្រុមបុគ្គលិកពេទ្យរបស់អង្គការលីកាដូ




ពន្ធនាគារដែលត្រូវបានចុះពិនិត្យដោយក្រុមបុគ្គលិកពេទ្យ

ពន្ធនាគារដែលមិនត្រូវបានចុះពិនិត្យដោយក្រុមបុគ្គលិកពេទ្យ

ចំនួននៃការពិនិត្យសុខភាពដែលធ្វើឡើងដោយក្រុមបុគ្គលិកពេទ្យលីកាដូ ត្រូវបានបង្ហាញដូចខាងក្រោមៈ

**ចំនួនអ្នកទោសក្នុងពន្ធនាគារទាំង១២ ដែលបានទទួលការព្យាបាលពីក្រុមពេទ្យលីកាដូ ២០០៧-២០០៨**




**ចំនួនមន្ត្រីពន្ធនាគារនៅក្នុងពន្ធនាគារទាំង១២ ដែលទទួលការព្យាបាលពីក្រុមពេទ្យលីកាដូ ២០០៧-២០០៨**



# ២. ស្ត្រីក្នុងពន្ធនាគារ

ត្រឹមចុងឆ្នាំ២០០៨ មានអ្នកទោសស្ត្រី ៦២៧ នាក់ ជាប់ឃុំឃាំងនៅក្នុងពន្ធនាគារចំនួន ១៨ ក្នុងចំណោមពន្ធនាគារទាំង ២៦ របស់កម្ពុជា និងមានចំនួនប្រហែល ៦ ភាគរយ នៃចំនួនអ្នកទោសទាំងអស់។

**ចំនួនអ្នកទោសស្ត្រីក្នុងពន្ធនាគារទាំង ១៨ ឃ្លាំមើលដោយលីកាដូ ចាប់តាំងពីឆ្នាំ២០០១-២០០៨**




**ចំនួនអ្នកទោសស្ត្រីក្នុងពន្ធនាគារនីមួយៗ ក្នុងចំណោមពន្ធនាគារទាំង១៨**
**ឃ្លាំមើលដោយ លីកាដូ ចាប់តាំងពីឆ្នាំ២០០៤-២០០៨**

| ពន្ធនាគារ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ៥ | ៦ | ៧ | ៨ | ១៥ |
| មណ្ឌលអប់រំកែប្រែទី១ (ម-១) | 0 | 0 | 0 | 0 | 0 |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ១៦៦ | ២៥៣ | ២៨០ | ២៦២ | ២៨៥ |
| មណ្ឌលអប់រំកែប្រែទី៣ (ម-៣) | 0 | 0 | 0 | 0 | 0 |
| ទួលស្លែង | 0 | 0 | 0 | 0 | 0 |

| | | | | | |
|---|---|---|---|---|---|
| តាខ្មៅ | ១៤ | ១៦ | ២៦ | ២៦ | ២៩ |
| ព្រះសីហនុ | ២១ | ១០ | ៧ | ១៦ | ២២ |
| ខេត្តកំពង់ស្ពឺ | ៥ | ៨ | ៧ | ៧ | ១០ |
| ខេត្តកំពត | ១៣ | ១៣ | ១៣ | ១៥ | ១៨ |
| ខេត្តកំពង់ឆ្នាំង | ៦ | ៩ | ៩ | ១៣ | ២១ |
| ខេត្តកំពង់ចាម | ២០ | ១៨ | ២៣ | ២៦ | ១៩ |
| ខេត្តកំពង់ធំ | ១១ | ១៤ | ៧ | ១១ | ១៧ |
| ខេត្តកោះកុង | ៦ | ១១ | ១០ | ៨ | ៨ |
| ខេត្តពោធិ៍សាត់ | ២៩ | ១០ | ៤ | ៧ | ១០ |
| ខេត្តបាត់ដំបង | ២១ | ៤៥ | ៤២ | ៣៥ | ៤៥ |
| ខេត្តបន្ទាយមានជ័យ | ២៣ | ៣៥ | ៤៩ | ៤៨ | ៤៤ |
| ខេត្តសៀមរាប | ២ | ៥២ | ៥៩ | ៧៤ | ៧៦ |
| ខេត្តស្វាយរៀង | ៣ | ៦ | ៩ | ១៤ | ៨ |
| **សរុប** | **៣៨៥** | **៥០៦** | **៥៥២** | **៥៧០** | **៦២៧** |

អ្នកទោសស្ត្រីជាប់ពន្ធនាគារដោយសារមូលហេតុជាច្រើន។ មូលហេតុសំខាន់មួយចំនួនមានដូចជា:

- ជួញដូរមនុស្ស (អាជីវកម្មផ្លូវភេទ)
- ជួញដូរថ្នាំញៀន (អ្នកចរាចរថ្នាំញៀន)
- ឃាតកម្ម (ជាទូទៅដើម្បីការការពារខ្លួនពីអំពើហិង្សាក្នុងគ្រួសារ[៥]) និង
- អំពើប្លន់ (ការលួចដោយហិង្សា)

ខាងក្រោមនេះជាស្ថិតិដែលប្រមូលដោយអ្នកស្រាវជ្រាវពន្ធនាគាររបស់ លីកាដូ ពេលសម្ភាសន៍ជាមួយអ្នកទោស ហើយស្ថិតិដែលផ្ដល់ជូនដោយអគ្គនាយកដ្ឋានពន្ធនាគារ។ ស្ថិតិទាំងនេះ បង្ហាញនូវប្រភេទបទល្មើស ដែលអ្នកទោសបានប្រព្រឹត្ត ប៉ុន្តែតួលេខនេះគ្រាន់តែតំណាងឱ្យអ្នកទោសប្រហែលជាពាក់កណ្ដាលនៃចំនួនអ្នកទោសសរុបតែប៉ុណ្ណោះ។ ដ្យាក្រាមបង្ហាញប្រភេទបទល្មើសសំខាន់ៗដែលបានប្រព្រឹត្ត សម្រាប់ធ្វើការប្រៀបធៀប ហើយតារាងបង្ហាញនូវប្រភេទបទល្មើសដែលអ្នកទោសបានប្រព្រឹត្តទាំងអស់។

[៥] កិច្ចការពារខ្លួនមិនត្រូវបានចាត់ទុកថាជាអំពើស្របច្បាប់ទេ នៅក្នុងច្បាប់នានានៅកម្ពុជា ហើយក្នុងការអនុវត្តជាក់ស្ដែង ចៅក្រមអាចលើក ឬអាចមិនលើកយកករណីបែបនេះមកពិចារណាឱ្យបានត្រឹមត្រូវនៅក្នុងការវិនិច្ឆ័យឡើយ។

## ចំនួនអ្នកទោសតាមប្រភេទបទល្មើស ឆ្នាំ២០០៧






| ចំនួនអ្នកទោសតាមប្រភេទបទល្មើស ឆ្នាំ២០០៧ | | |
|---|---|---|
| **ប្រភេទបទល្មើស** | **បុរស** | **ស្ត្រី** |
| សំលាប់ | ៩៦២ | ៨៤ |
| ប្លន់ និងសំលាប់ | ៣៨៤ | ១២ |
| ប្លន់ | ១៦៥១ | ៧៦ |
| បង្កអគ្គិសភ័យ | ១៦ | ១ |
| រំលោភ និងសំលាប់ | ១២២ | ០ |
| រំលោភ | ៥២៨ | ៤ |
| រៀបចំបទល្មើស និងភេរវកម្ម | ៤៤ | ១ |
| ចាប់ជំរិត | ៧២ | ៩ |
| បង្ខាំងមនុស្សខុសច្បាប់ | ១៤ | ០ |
| ជួញដូរមនុស្ស | ៤៣ | ១៧២ |
| ជួញដូរថ្នាំញៀន | ១៤៥ | ៧៧ |
| ប្រើប្រាស់គ្រឿងញៀន | ៧៣ | ៩ |
| អំពើលួច | ៦៨៨ | ៣៣ |
| ទទួលយករបស់ពីចោរ | ៦៣ | ៥ |
| បង្ករបួសស្នាម | ៣២១ | ១១ |
| បន្លំឯកសារសាធារណៈ | ១៧ | ៥ |
| ឆបោក | ៤៨ | ២៥ |
| រំលោភលើសេចក្ដីទុកចិត្ត | ៤៣ | ៥ |
| បៀតបៀនកេរ្ដិ៍ខ្មាស់ | ១៩ | ០ |
| បរិហាកេរ្ដិ៍ | ៥ | ០ |
| ប្រើប្រាស់អាវុធខុសច្បាប់ | ៧៩ | ១០ |
| បំផ្លាញទ្រព្យសម្បត្តិ | ៦២ | ៣ |
| បង្កគ្រោះថ្នាក់ចរាចរ | ៩ | ០ |
| នេសាទខុសច្បាប់ | ៦ | ០ |
| ផ្សេងៗ | ២៣៣ | ៨ |
| **សរុប** | **៥៦០៧** | **៥៥០** |

## ករណីសិក្សា: អំពើលួច

នាងខ្ញុំឈ្មោះ សុភ័ក្រ។ គ្រួសាររបស់នាងខ្ញុំក្រណាស់។ ពេលដែលឪពុករបស់នាងខ្ញុំស្លាប់ទៅ នាងខ្ញុំក្លាយជាអ្នកទទួលខុសត្រូវ ក្នុងការរកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

កាលពីដើមឆ្នាំ២០០៨ នាងខ្ញុំបានលួចលុយអ្នកជម្ងឺម្នាក់ នៅមន្ទីរពេទ្យខេត្តមួយ ហើយនាងខ្ញុំត្រូវគេចាប់ និងបញ្ជូនខ្លួនទៅឃុំឃាំងក្នុងពន្ធនាគារ។ តែទោះជាយ៉ាងណា នាងខ្ញុំត្រូវបានដោះលែងមកវិញកាលពីពីរបីខែកន្លងទៅ ប៉ុន្តែខ្ញុំមិនបានចាំថាពេលណានោះទេ។ នៅចុងឆ្នាំ២០០៨ នាងខ្ញុំបានលួចលុយរបស់គេម្តងទៀត ហើយនាងខ្ញុំត្រូវបានចាប់ និងបញ្ជូនខ្លួនទៅឃុំឃាំង ដើម្បីរង់ការកាត់ទោស។ ពីរបីសប្តាហ៍ក្រោយមក តុលាការបានបើកសវនការលើករណីរបស់នាងខ្ញុំ ហើយបានកាត់ទោសនាងខ្ញុំឱ្យជាប់ពន្ធនាគាររយៈពេល ៣ ឆ្នាំ។

នាងខ្ញុំជាប់ឃុំឃាំងនៅបន្ទប់ឃុំឃាំងមួយជាមួយអ្នកទោសស្ត្រី ១៦ នាក់ ផ្សេងទៀត។ ពួកយើងត្រូវគេអនុញ្ញាតឱ្យចេញមកក្រៅបន្ទប់ឃុំឃាំងពីរដងក្នុងមួយថ្ងៃ គឺបានច្រើនដងជាងអ្នកទោសបុរស។ នាងខ្ញុំឃើញថា នៅទីនេះ អាហារមិនឆ្ងាញ់ ហើយមិនគ្រប់គ្រាន់ទៀត។ គុណភាពម្ហូបអាហារក៏កត្តាមួយដែលបណ្តាលឱ្យមានបញ្ហាសុខភាព និងបញ្ហាកង្វះជីវជាតិផងដែរ។

## ចំនួនអ្នកទោសតាមប្រភេទបទល្មើស ឆ្នាំ២០០៨



| ចំនួនអ្នកទោសតាមប្រភេទបទល្មើស ឆ្នាំ២០០៨ | | |
|---|---|---|
| **ប្រភេទបទល្មើស** | **បុរស** | **ស្ត្រី** |
| សំលាប់ | ១០៤៨ | ៩៥ |
| ប្លន់ និងសំលាប់ | ២៦៩ | ៧ |
| ប្លន់ | ២១៧៥ | ៨៨ |
| បង្កអគ្គិសភ័យ | ១៣ | ២ |
| រំលោភ និងសំលាប់ | ១០៩ | ០ |
| រំលោភ | ៦៧៤ | ៤ |
| រៀបចំបទល្មើស និងភេរវកម្ម | ៤០ | ១ |
| ចាប់ជំរិត | ១០២ | ៧ |
| បង្ខាំងមនុស្សខុសច្បាប់ | ១៤ | ០ |
| ជួញដូរមនុស្ស | ៥៩ | ១៩៦ |
| ជួញដូរថ្នាំញៀន | ១៦៥ | ៩៣ |
| ប្រើប្រាស់គ្រឿងញៀន | ៧៨ | ៨ |
| អំពើលួច | ៤១៣ | ២៨ |
| ទទួលយករបស់ពីចោរ | ៧ | ១ |
| បង្ករបួសស្នាម | ៣១៣ | ៩ |
| បន្លំឯកសារសាធារណៈ | ១៧ | ៥ |
| ឆបោក | ៦២ | ៣៩ |
| រំលោភលើសេចក្តីទុកចិត្ត | ៣៩ | ១៦ |
| បៀតបៀនក្តីខ្មាស់ | ១៩ | ០ |
| បរិហាកេរ្តិ៍ | ៤ | ០ |
| ប្រើប្រាស់អាវុធខុសច្បាប់ | ៦៧ | ២ |
| បំផ្លាញទ្រព្យសម្បត្តិ | ៦៧ | ២ |
| ឆ្លងដែនខុសច្បាប់ | ០ | ១ |
| បង្កគ្រោះថ្នាក់ចរាចរ | ៦ | ១ |

| | | |
|---|---|---|
| នេសាទខុសច្បាប់ | ៣ | ០ |
| ផ្សេងៗ | ២៧៩ | ១០ |
| **សរុប** | **៦០៤២** | **៦១៥** |

**ករណីសិក្សា: ការសម្លាប់ និងអំពើហិង្សាក្នុងគ្រួសារដែលកើតចេញពីបុរស**

នាងខ្ញុំឈ្មោះសុភាព អាយុ ៤៩ ឆ្នាំ។ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ១៩៧៩ ហើយមានកូន ៧ នាក់។ ពេលទើបរៀបជីវិតអាពាហ៍ពិពាហ៍ គ្រួសាររបស់នាងខ្ញុំមានសុភមង្គល។ ក៏ប៉ុន្តែបន្ទាប់ពីនាងខ្ញុំមានកូនដំបូងរួចមក អ្វីៗមានការផ្លាស់ប្តូរ ហើយអំពើហិង្សាក៏ចាប់ផ្តើមកើតមានដែរ។ រៀងរាល់ថ្ងៃ ប្តីរបស់នាងខ្ញុំមិនសូវនៅផ្ទះទេ។ ពេលគាត់ត្រឡប់មកផ្ទះវិញ គាត់តែងតែស្រវឹងជោគជាំ ហើយគាត់ធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្តមកលើកូនៗ និងរូបនាងខ្ញុំ ហើយជួលកាលរួមទាំងអ្នកជិតខាងថែមទៀត។

ការធ្វើបាប និងអំពើហិង្សាបានក្លាយជារឿងធម្មតាទៅហើយនៅក្នុងគ្រួសាររបស់នាងខ្ញុំ។ រៀងរាល់សប្តាហ៍ប្តីរបស់នាងខ្ញុំតែងតែរករឿងខឹងសម្បាពីនេះពីនោះ។ ពេលខ្លះ គាត់ច្រណែនចំពោះការចំណាយពេលវេលា និងការយកចិត្តទុកដាក់ដែលនាងខ្ញុំមានចំពោះកូនប្រុស និងកូនប្រសាររបស់នាងខ្ញុំ។ អ្នករស់នៅក្បែរខាងនាងខ្ញុំក៏ធ្លាប់បានដឹងអំពីបញ្ហាអំពើហិង្សានេះដែរ ហើយរឿងនេះបានក្លាយជាផ្នែកមួយនៅក្នុងឆាកជីវិតរបស់យើងទៅហើយ។

ក្នុងយប់មួយនាឆ្នាំ២០០៨ ប្តីរបស់នាងខ្ញុំត្រឡប់មកផ្ទះវិញស្រវឹងជោគជាំ ហើយបានឈ្លោះប្រកែកជាមួយកូនប្រុសរបស់នាងខ្ញុំ។ ពេលនោះ នាងខ្ញុំបានចូលទៅឃាត់ ហើយគាត់ក៏ស្រែកគំហក និងដាល់នាងខ្ញុំ។ នាងខ្ញុំដួលទៅលើដី ហើយគាត់បានទាត់ធាក់នាងខ្ញុំ រហូតដល់នាងខ្ញុំសន្លប់បាត់ស្មារតី។ ពេលនាងខ្ញុំដឹងខ្លួនវិញ នាងខ្ញុំឃើញគាត់ឈរជាន់ពីលើនាងខ្ញុំ ហើយកាន់ពូថៅមួយទៀត។ ពេលនោះ នាងខ្ញុំក៏រុញគាត់ចេញ ហើយស្ទុះទៅយកកាំបិតពីចង្ក្រានបាយ។ នាងខ្ញុំបិទភ្នែក ហើយធ្វើសកម្មភាពដើម្បីការពារខ្លួននាងខ្ញុំ។ ពេលនាងខ្ញុំបើកភ្នែកឡើង នាងខ្ញុំឃើញគាត់ដេកនៅលើឥដ្ឋ ហើយប្រឡាក់ទៅដោយឈាម។ ពេលនោះគាត់មិនទាន់ស្លាប់ភ្លាមនោះទេ ប៉ុន្តែបន្តិចក្រោយមកគាត់ក៏ដាច់ខ្យល់ស្លាប់ទៅ។

បន្ទាប់មក នាងខ្ញុំត្រូវគេបញ្ជូនខ្លួនមកកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាល ហើយបន្ទាប់មកបញ្ជូនទៅឃុំឃាំងបណ្តោះអាសន្នក្នុងពន្ធនាគារដើម្បីរង់ចាំសវនាការ។

នាងខ្ញុំមិនចង់ឱ្យមានរឿងបែបនេះកើតឡើងនៅក្នុងគ្រួសាររបស់នាងខ្ញុំទេ។ នាងខ្ញុំមិនចង់សម្លាប់ប្តីរបស់នាងខ្ញុំទេ ក៏ប៉ុន្តែនាងខ្ញុំមិនអាចស៊ូទ្រាំរស់នៅក្នុងស្ថានភាពបែបនេះបានឡើយ។ អ្វីដែលនាងខ្ញុំបានធ្វើគឺគ្រាន់តែដើម្បីការពារក្រុមគ្រួសាររបស់នាងខ្ញុំឱ្យរួចផុតអំពើហិង្សាដដែលៗ តែប៉ុណ្ណោះ។

## ករណីសិក្សាៈ ការជួញដូរគ្រឿងញៀន

នាងខ្ញុំឈ្មោះ សុផាត អាយុ ៦៧ ឆ្នាំ។ នាងខ្ញុំត្រូវបានចាប់ខ្លួន ដោយសារកូនប្រុសនាងខ្ញុំជាអ្នកជួញគ្រឿងញៀន។ ជាធម្មតា កូនប្រុសនាងខ្ញុំតែងតែឱ្យកញ្ចប់មកនាងខ្ញុំ ដើម្បីរក្សាទុកនៅក្នុងផ្ទះ ប៉ុន្តែនាងខ្ញុំមិនបានដឹងថា មានអ្វីក្នុងកញ្ចប់ទាំងនោះទេ។ ថ្ងៃមួយ ពេលកូនប្រុសរបស់នាងខ្ញុំចេញទៅធ្វើការ នរគបាលបានមកផ្ទះរបស់នាងខ្ញុំ។ នាងខ្ញុំមិនបានដឹងថា នរគបាលចង់រកអ្វីនោះទេ។ ពួកគេបានសម្រុកចូលក្នុងផ្ទះ ហើយនិយាយថា ពួកគេកំពុងតែស្វែងរករបស់ម្យ៉ាង។ ពួកគេឆែកឆេរផ្ទះនាងខ្ញុំ ហើយរកឃើញកញ្ចប់របស់កូនប្រុសនាងខ្ញុំ។ នរគបាលនិយាយប្រាប់ថា "នេះគឺជាគ្រឿងញៀន" ហើយថាខ្ញុំគឺជាអ្នកជួញដូរគ្រឿងញៀន។ ខ្ញុំមិនស្គាល់ថា គ្រឿងញៀនយ៉ាងម៉េចនោះទេ ហើយកាន់តែមិនដឹងថាមាននៅក្នុងផ្ទះខ្ញុំនោះឡើយ។ បន្ទាប់មក នាងខ្ញុំត្រូវបានបញ្ជូនខ្លួនទៅកាន់ប៉ុស្តិ៍នរគបាល។

នៅថ្ងៃដដែល នាងខ្ញុំត្រូវបានបញ្ជូនមកកាន់តុលាការជាមួយស្ត្រីពីរនាក់ទៀតដែលនាងខ្ញុំមិនស្គាល់។ តុលាការបានចោទប្រកាន់ពួកយើងទាំងបី ពីបទជួញដូរគ្រឿងញៀន។ ស្ត្រីទី១ ធ្វើការនៅកាស៊ីណូ ត្រូវបានចោទថា បានលក់គ្រឿងញៀននៅទីនោះ ហើយស្ត្រីម្នាក់ទៀតជាជាងអ៊ុតសក់ ត្រូវបានចោទថា ជាអ្នកចែកចាយគ្រឿងញៀន។ តុលាការបានសម្រេចកាត់ទោសយើងទាំង ៣ នាក់ ដាក់ពន្ធនាគារម្នាក់រយៈពេល ២ ឆ្នាំ ពីបទជួញដូរគ្រឿងញៀន។ រឿងទាំងនេះ បានកើតឡើងនៅចំថ្ងៃតែមួយ ហើយវាហាក់ដូចជាលឿនណាស់ ហើយនាងខ្ញុំមានការរន្ធត់ចិត្តយ៉ាងខ្លាំង។

នៅក្នុងពន្ធនាគារ នាងខ្ញុំជួយបោកសម្លៀកបំពាក់ឱ្យមន្ត្រីពន្ធនាគារ និងធ្វើការនៅក្នុងផ្ទះបាយ។ ពួកយើងមានសំណាង ពីព្រោះយើងត្រូវបានអនុញ្ញាតឱ្យចេញក្រៅបន្ទប់ឃុំឃាំងជារៀងរាល់ព្រឹក ហើយអ្នកទោសស្ត្រីក៏មានចំនួនតិចដែរនៅក្នុងពន្ធនាគារ (ចំនួនតិចជាងអ្នកទោសបុរសច្រើន) ដូច្នេះយើងមិនសូវមានការលំបាក ឬបញ្ហាច្រើននោះទេ។

## ករណីសិក្សាៈ ការជួញដូរមនុស្សសម្រាប់សូមកូន

នាងខ្ញុំឈ្មោះ គា កើតនៅឆ្នាំ១៩៨០។ នាងខ្ញុំបានរៀបការនៅឆ្នាំ២០០០ ហើយមានកូនមួយនាក់។ នាងខ្ញុំត្រូវបានចាប់ខ្លួននៅឆ្នាំ២០០៨ ក្រោមការចោទប្រកាន់ពីបទជួញដូរមនុស្សក្នុងគោលបំណងសូមកូន។

កាលពីមុន នាងខ្ញុំធ្លាប់បានទៅសួរសុខទុក្ខបងស្រី និងបងប្រុសថ្លៃរបស់នាងខ្ញុំ រួមទាំងកូនស្រីរបស់ពួកគាត់អាយុ ៧ ឆ្នាំផង។ ពេលមួយនោះ នាងខ្ញុំបានយកកូនរបស់ពួកគាត់ ធ្វើដំណើរទៅខេត្តមួយផ្សេងទៀត ដោយពុំបានប្រាប់ពួកគាត់។ ហេតុនេះ បងស្រីរបស់នាងខ្ញុំបានប្តឹងនគរបាល ចោទប្រកាន់ខ្ញុំពីបទជួញ

ដូរមនុស្ស ក្នុងគោលបំណងសូមកូន ហើយនគរបាលក៏បានចាប់ខ្លួននាងខ្ញុំ។

ឥឡូវនេះ នាងខ្ញុំកំពុងជាប់ឃុំឃាំងបណ្ដោះអាសន្នដើម្បីរង់ចាំសវនការ នៅក្នុងបន្ទប់ឃុំឃាំងមួយដ៏ចង្អៀត បរិយាកាសអាប់អួរ និងពិបាកដកដង្ហើម។ ទោះបីជាយ៉ាងណា គេអនុញ្ញាតឱ្យនាងខ្ញុំចេញពីបន្ទប់ឃុំឃាំងរៀងរាល់ព្រឹក។ ចំពោះអាហារវិញ នាងខ្ញុំទទួលបានអាហារចំនួនពីពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច ប៉ុន្តែវាមិនគ្រាប់គ្រាន់នោះទេ។ កាលពីដំបូង នាងខ្ញុំពិបាកទ្រាំនឹងស្ថានភាពបែបនេះណាស់ ប៉ុន្តែមួយរយៈពេលក្រោយមក នាងខ្ញុំមានភាពស៊ាំងនឹងស្ថានភាពបែបនេះ។ ពេលខ្លះ នាងខ្ញុំត្រូវបោកគក់សម្លៀកបំពាក់ ដើម្បីមានឱកាសចេញមកខាងក្រៅបន្ទប់ឃុំឃាំងឱ្យបានច្រើន និងទទួលបានអាហារបន្ថែមទៀត។ នៅក្នុងពន្ធនាគារ នាងខ្ញុំពុំបានទទួលការថែទាំសុខភាពឱ្យបានត្រឹមត្រូវនោះទេ។ ពេលដែលនាងខ្ញុំឈឺ នាងខ្ញុំពុំបានទទួលការព្យាបាលអ្វីសោះ ឬសូម្បីថ្នាំសម្រាប់លេបក៏អត់ដែរ។

បច្ចុប្បន្ននេះ នាងខ្ញុំកំពុងរង់ចាំសវការ ប៉ុន្តែនាងខ្ញុំមិនដឹងថាតើ សវនាការនឹងត្រូវរៀបចំឡើងនៅពេលណានោះទេ។

## ករណីសិក្សាៈ ប្លន់ និងសម្លាប់

នាងខ្ញុំឈ្មោះ ស៊ុន ឡាង អាយុ ២៥ ឆ្នាំ។ នាងខ្ញុំត្រូវបានចាប់ខ្លួនពីបទប្លន់ និងសម្លាប់។ កាលពីឆ្នាំ២០០៧ នាងខ្ញុំបានសម្លាប់ស្ត្រីម្នាក់ អាយុ ៧០ ឆ្នាំ ដើម្បីយកគ្រឿងអលង្ការរបស់គាត់។ នៅថ្ងៃបន្ទាប់ នាងខ្ញុំត្រូវបានគេចាប់ និងបញ្ជូនខ្លួនមកទទួលការឃុំខ្លួនបណ្ដោះអាសន្ន។ ពីរបីខែក្រោយមក នាងខ្ញុំត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១៥ ឆ្នាំ។

នៅក្នុងពន្ធនាគារ នាងខ្ញុំជាប់នៅក្នុងបន្ទប់ឃុំឃាំងមួយ ជាមួយនឹងអ្នកទោសស្ត្រីផ្សេងៗ ហើយពួកយើងត្រូវបានគេអនុញ្ញាតឱ្យចេញមកក្រៅបន្ទប់ជារៀងរាល់ព្រឹក។ នាងខ្ញុំតែងតែលេងល្បែងកំសាន្តជាមួយនឹងអ្នកទោសបុរសផ្សេងទៀត ពេលដែលយើងបានចេញមកក្រៅស្របពេលគ្នា។ នាងខ្ញុំមិនមានសាច់ញាតិមកសួរសុខទុក្ខទេ។ មនុស្សម្នាគិតថា នាងខ្ញុំជាមនុស្សមានបញ្ហាផ្លូវចិត្ត ដែលបានប្រព្រឹត្តរឿងមិនសមរម្យមួយចំនួន។ មានពេលខ្លះ នាងខ្ញុំបានរួមភេទជាមួយនឹងអ្នកទោសបុរស។ មន្ត្រីពន្ធនាគារ និងបុគ្គលិកអង្គការតែងតែប្រាប់ និងផ្តល់ដំបូន្មានខ្ញុំឱ្យឈប់ប្រព្រឹត្តបែបនោះទៀត ប៉ុន្តែខ្ញុំមិនដែលធ្វើតាមដំបូន្មានរបស់ពួកគេឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ជំនួយមកឱ្យពួកយើងជាញឹកញាប់ ដោយពួកគាត់មានសេចក្តីអាណិតអាសូរ ចំពោះស្ថានភាពលំបាករបស់ពួកយើង។ នាងខ្ញុំមានសំណាង ដោយបានទទួលការឧបត្ថម្ភ ហើយបានរស់នៅមានសេរីភាពច្រើនជាងអ្នកទោសបុរស។

## ករណីសិក្សា: ការសម្លាប់ និងអំពើហិង្សាក្នុងគ្រួសារដែលកើតចេញពីឪពុកម្តាយ

នាងខ្ញុំឈ្មោះ ស្រីនាង អាយុ ២៥ ឆ្នាំ។ នាងខ្ញុំបានរៀបការនៅក្នុងឆ្នាំ២០០៥ ហើយមានកូនប្រុស ១ នាក់។ បន្ទាប់ពីរៀបការបាន ៥ ខែ នាងខ្ញុំបានផ្លាស់ប្តូរទីលំនៅមករស់នៅផ្ទះថ្មី ហើយជីវិតអាពាហ៍ពិពាហ៍របស់យើងក៏ប្រកបដោយភាពរីករាយ និងសុភមង្គលផងដែរ។ ប៉ុន្តែ ឪពុកខ្ញុំមិនមានការសប្បាយចិត្តជាមួយប្តីរបស់នាងខ្ញុំ និងនាងខ្ញុំទេ។ ខ្ញុំមិនដឹងថាមកពីហេតុអ្វីឡើយ។ គាត់ចូលចិត្តបង្កឱ្យមានជម្លោះ ហើយជេរនាងខ្ញុំ។ នាងខ្ញុំបានស៊ូទ្រាំអត់ធ្មត់ចំពោះអាកប្បកិរិយារបស់គាត់ ពីព្រោះគាត់ជាឪពុករបស់នាងខ្ញុំ។

មានថ្ងៃមួយកូនប្រុសរបស់នាងខ្ញុំបានទៅលេងក្រោមផ្ទះគាត់ដូចសព្វមួយដង។ ពេលម៉ោងបាយថ្ងៃត្រង់ នាងខ្ញុំបានទៅហៅកូនឱ្យមកហូបបាយ។ ឪពុករបស់ខ្ញុំបាននៅទីនោះ ហើយបានចាប់ផ្តើមឈ្លោះប្រកែកជាមួយនាងខ្ញុំ។ គាត់ខឹងច្រឡោតយ៉ាងខ្លាំង ហើយបានដាល់មុខនាងខ្ញុំ។ ពេលកំពុងវាយតប់គ្នានោះ នាងខ្ញុំចាប់យកកាំបិត ហើយចាក់ពោះ និងទ្រូងគាត់ជាច្រើនដង រហូតដល់ឈាមប្រឡាក់ពេញខ្លួនគាត់។

នគរបាលចាប់ខ្លួននាងខ្ញុំយកទៅ។ នាងខ្ញុំត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១០ ឆ្នាំ ពីបទសម្លាប់ឪពុកខ្លួនឯង។ បងប្អូនប្រុសស្រីរបស់នាងខ្ញុំ ចាត់ទុកនាងខ្ញុំជាឃាតករសម្លាប់ឪពុកខ្លួនឯង។ ប៉ុន្តែពួកគេពុំបានដឹងទេថា ឪពុករបស់នាងខ្ញុំបានប្រព្រឹត្តបែបណាមកលើរូបនាងខ្ញុំនោះទេ ហើយគាត់ក៏មិនដែលស្រឡាញ់កូនស្មើគ្នាដែរ។ មិនមានញាតិមិត្ត ឬក៏បងប្អូនមកសួរសុខទុក្ខនាងខ្ញុំទេ គឺមានតែប្តី និងអ្នកជិតខាងរបស់នាងខ្ញុំតែប៉ុណ្ណោះ ដែលបានមកលេងម្តងម្កាល។ នាងខ្ញុំមានអារម្មណ៍ក្រៀមក្រំយ៉ាងខ្លាំង ពេលនាងខ្ញុំគិតដល់អ្វីដែលបានកើតឡើង ក្នុងឆាកជីវិតរបស់នាងខ្ញុំ។

នៅក្នុងពន្ធនាគារ នាងខ្ញុំអាចចេញក្រៅបន្ទប់ឃុំឃាំងបានជារៀងរាល់ព្រឹក ដើម្បីមកដាំបាយ និងដួសទឹក។ ពេលខ្លះ នាងខ្ញុំត្រូវបោកសម្លៀកបំពាក់ឱ្យមន្ត្រីពន្ធនាគារ ជាថ្នូរនឹងការចេញមកខាងក្រៅរៀងរាល់ព្រឹក។ នាងខ្ញុំយល់ថា នាងខ្ញុំមានសេរីភាពជាងអ្នកទោសបុរស។ ប៉ុន្តែ វានៅតែជាពន្ធនាគារដដែល។



## ករណីសិក្សា: ការជួញដូរមនុស្សសម្រាប់អាជីវកម្មផ្លូវភេទ

នាងខ្ញុំឈ្មោះ ងុក យាវ ។ នាងខ្ញុំកើតនៅឆ្នាំ១៩៨៦ នៅប្រទេសវៀតណាម ហើយនាងខ្ញុំបានមករស់នៅប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦ ដើម្បីបើកហាងម៉ាស្សា។ នាងខ្ញុំក៏បានជួលក្មេងស្រីជនជាតិវៀតណាមពីរបីនាក់ ដើម្បីធ្វើការនៅក្នុងហាងរបស់នាងខ្ញុំ ។

ថ្ងៃមួយក្នុងឆ្នាំ២០០៨ នគរបាលប្រឆាំងការជួញដូរមនុស្សបានមកដល់ផ្ទះខ្ញុំ។ ពួកគាត់បានចោទប្រកាន់នាងខ្ញុំពីបទជួញដូរមនុស្ស និងជួលក្មេងស្រីមិនគ្រប់អាយុឱ្យធ្វើការ និងរកស៊ីផ្លូវភេទ។ នាងខ្ញុំក៏បានប្រាប់ពួកគាត់ថា នាងខ្ញុំគ្រាន់តែរកស៊ីធម្មតា មិនបានរកស៊ីផ្លូវភេទនោះទេ។ នាងខ្ញុំគ្រាន់តែជួលស្ត្រីដែលស្ម័គ្រចិត្តមកធ្វើការឱ្យខ្ញុំតែប៉ុណ្ណោះ។ ប៉ុន្តែវាឥតប្រយោជន៍នោះទេ ព្រោះនគរបាលបានចាប់ខ្លួន និងបញ្ជូនខ្លួននាងខ្ញុំទៅឃុំឃាំង ដើម្បីរង់ចាំសវនាការ ។

ឥឡូវ នាងខ្ញុំកំពុងជាប់នៅក្នុងបន្ទប់ឃុំឃាំងតូចមួយ ជាមួយស្ត្រីប្រហែល ១០ នាក់ផ្សេងទៀត។ នៅក្នុងបន្ទប់ឃុំឃាំងនេះ យើងពិបាកដកដង្ហើម ហើយពិបាកគេងទៀត ពីព្រោះបន្ទប់នេះតូចចង្អៀត។ បន្ទប់នេះមានភាពកខ្វក់ និងមានក្លិនមិនល្អ ហើយពួកយើងថែមទាំងមិនមានទឹកគ្រប់គ្រាន់ សម្រាប់ងូតទៀតផង។ តែទោះជាយ៉ាងណា ខ្ញុំបានឃើញថា មន្ត្រីពន្ធនាគារមិនរើសអើងចំពោះនាងខ្ញុំ ដែលជាជនជាតិវៀតណាមនោះឡើយ ។

## ករណីសិក្សា: ករណីឆបោក

នាងខ្ញុំឈ្មោះ រស្មី អាយុ ៤០ ឆ្នាំ។ នាងខ្ញុំត្រូវបានចាប់ខ្លួនពីបទឆបោក។ នាងខ្ញុំរស់នៅទីក្រុងភ្នំពេញ ហើយបានធ្វើដំណើរទៅកាន់បណ្តាខេត្តមួយចំនួន ដើម្បីធ្វើការទំនាក់ទំនងជាមួយមនុស្សផ្សេងៗគ្នា។ នៅក្នុងខេត្តមួយនោះ នាងខ្ញុំបានចាប់ផ្តើមកសាងទំនាក់ទំនងជាមួយដូនជីម្នាក់នៅក្នុងវត្តមួយ។ ពីរបីក្រោយមក នាងខ្ញុំនៅតែបន្តទៅសួរសុខទុក្ខដូនជីនោះ ហើយគាត់ក៏ចាប់ផ្តើមជឿទុកចិត្តនាងខ្ញុំដែរ។ ដូនជីនោះតែងតែប្រាប់នាងខ្ញុំអំពីគម្រោងរបស់គាត់ក្នុងការជួសជុលវត្តនោះ។

ថ្ងៃមួយ នាងខ្ញុំបានបញ្ចុះបញ្ចូលដូនជីនោះ ឱ្យលុយមកនាងខ្ញុំចំនួន ២០០ ០០០ រៀល (ប្រហែល ៥០ ដុល្លារ) ដើម្បីទិញស៊ីម៉ង់ត៍ យកទៅប្រើសម្រាប់ការជួសជុលវត្តនោះ។ នៅពេលដែលពីដូនជីនោះឱ្យលុយមកនាងខ្ញុំ នាងខ្ញុំបានវិលត្រលប់មកភ្នំពេញវិញ ហើយមិនបានទិញស៊ីម៉ង់ត៍តាមការសន្យាឡើយ។ នាងខ្ញុំបានចាយលុយទាំងអស់នោះ សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់នាងខ្ញុំ។ ពីរបីសប្តាហ៍ក្រោយមក

នាងខ្ញុំបានវិលត្រលប់ទៅកាន់វត្តនោះម្តងទៀត ហើយនាងខ្ញុំត្រូវនគរបាលចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងក្នុងពន្ធនាគារ ដើម្បីរង់ចាំការសវនាការ។

នាងខ្ញុំត្រូវបានឃុំនៅក្នុងបន្ទប់ឃុំឃាំងមួយជាមួយនឹងស្ត្រី ១៩ នាក់ ផ្សេងទៀត។ ទោះជាយ៉ាងណាបន្ទប់ឃុំឃាំងនោះ ហាក់ដូចជាធំជាងបន្ទប់ឃុំឃាំងបុរស ហើយនាងខ្ញុំអាចចេញមកក្រៅបន្ទប់ឃុំឃាំងបានរៀងរាល់ព្រឹក។ ពេលដែលនាងខ្ញុំចេញមកខាងក្រៅ ពេលខ្លះនាងខ្ញុំត្រូវបោកសម្លៀកបំពាក់ឱ្យមន្ត្រីពន្ធនាគារ ឬទៅយកទឹកមកលាងសម្អាតបន្ទប់ឃុំឃាំងនោះ។ បច្ចុប្បន្ននេះ នាងខ្ញុំកំពុងរង់ចាំសវនាការ ប៉ុន្តែនាងខ្ញុំមិនដឹងថាតើ សវនាការនោះនឹងធ្វើឡើងនៅពេលណានោះទេ។

## ចំនួនអ្នកទោស

ត្រឹមចុងឆ្នាំ២០០៨ ក្នុងចំណោមពន្ធនាគារទាំង១៨ ដែលឃ្លាំមើលដោយ លីកាដូ មានអ្នកទោសសរុបចំនួន ១០.៩៩២ នាក់[៦]។ ក្នុងនោះ អ្នកទោសបុរសមានចំនួន ៩.២៦២ នាក់ អ្នកទោសស្ត្រីមានចំនួន ៦២៧ និងអនីតិជនភេទប្រុសមានចំនួន ៦៨៤ នាក់ និងអនីតិជនភេទស្រីមានចំនួន ១៩ នាក់។

**ចំនួនអ្នកទោសក្នុងពន្ធនាគារទាំង១៨ ដែលបានស្រាវជ្រាវដោយលីកាដូពីឆ្នាំ ១៩៩៩-២០០៨**




[៦] យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ (ចេញផ្សាយនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨) នៅចុងខែធ្នូ ឆ្នាំ២០០៨ នេះ អ្នកទោសនៅក្នុងប្រទេសកម្ពុជា មានចំនួនសរុប ១១.៦៨៨ នាក់។

**លទ្ធភាពពន្ធនាគារទាំង ១៨ សម្រាប់ដាក់អ្នកទោស ដែលបានឃ្លាំមើលដោយលីកាដូ ឆ្នាំ២០០៨**

| ពន្ធនាគារ | លទ្ធភាពពន្ធនាគារ ២០០៨ | ចំនួនអ្នកទោស តុលា ២០០៨ | លទ្ធភាព | |
|---|---|---|---|---|
| | | | ២០០៦ | ២០០៨ |
| ប៉ៃលិន | ១០០ | ១៥៦ | ១៤៩% | ១៥៦% |
| ម-១ | ១.៥០០ | ២៥៥៨ | ១៤៧% | ១៧០% |
| ម-២ | ៣៥០ | ៦៥៩ | ១៦៦% | ១៨៨% |
| ម-៣ | ១.២០០ | ១៣៥៨ | ១០២% | ១១៣% |
| ទួលស្លែង | ៥០ | ២ | ១២% | ៤០% |
| តាខ្មៅ | ៣៥០ | ៧៤៦ | ១៨៦% | ២១៣% |
| ព្រះសីហនុ | ១០០ | ១៨៧ | ១៥០% | ១៨៧% |
| កំពង់ស្ពឺ | ២០០ | ៣៤០ | ១២៧% | ១៧០% |
| កំពត | ១៨០ | ២៦៧ | ១៣០% | ១៤៨% |
| កំពង់ឆ្នាំង | ១២០ | ២៦៣ | ១៦៦% | ២១៩% |
| កំពង់ចាម | ៤០០ | ៦៣៤ | ១២៦% | ១៥៨% |
| កំពង់ធំ | ៦០ | ២១២ | ២៤៥% | ៣៥៣% |
| កោះកុង | ១៤០ | ១៦០ | ៨២% | ១១៤% |
| ពោធិ៍សាត់ | ១០០ | ២១៧ | ៩៦% | ២១៧% |
| បាត់ដំបង | ៦០០ | ៩៣១ | ១៥១% | ១៥៥% |
| បន្ទាយមានជ័យ | ២០០ | ៥៤១ | ២៤៦% | ២៧០% |
| សៀមរាប | ៥៥០ | ១១៤២ | ១៧២% | ២០៧% |
| ស្វាយរៀង | ២១០ | ២១៩ | ១០៦% | ១០៤% |
| **សរុបជាមធ្យម** | **៦.៣៦៥** | **១០៥៩២** | **១៤៣%** | **១៦៦%** |

## ចំនួនទនអនីតិជនក្នុងពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយ លីកាដូ ពីឆ្នាំ២០០១-២០០៨




## ចំនួនអនីតិជនក្នុងពន្ធនាគារនីមួយៗ ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយ លីកាដូ ពីឆ្នាំ២០០៦-២០០៨

| ពន្ធនាគារ | ២០០៦ | | ២០០៧ | | ២០០៨ | |
|---|---|---|---|---|---|---|
| | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី |
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ០ | ០ | ០ | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី១ (ម-១) | ០ | ០ | ០ | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ២៩៤ | ៨ | ៣០៤ | ៩ | ៣៦៤ | ១០ |
| មណ្ឌលអប់រំកែប្រែទី៣ (ម-៣) | ០ | ០ | ០ | ០ | ០ | ០ |
| ទួលស្លែង | ០ | ០ | ០ | ០ | ០ | ០ |
| តាខ្មៅ | ៤៩ | ១ | ៤១ | ០ | ៥៤ | ៤ |
| ព្រះសីហនុ | ៦ | ០ | ៦ | ០ | ១៥ | ០ |
| ខេត្តកំពង់ស្ពឺ | ១១ | ០ | ១៥ | ០ | ១៥ | ០ |
| ខេត្តកំពត | ២ | ០ | ១៤ | ០ | ១៥ | ១ |
| ខេត្តកំពង់ឆ្នាំង | ៧ | ០ | ៧ | ០ | ៧ | ១ |

| | | | | | | |
|---|---|---|---|---|---|---|
| ខេត្តកំពង់ចាម | ៩ | ៣ | ២១ | ០ | ២៣ | ០ |
| ខេត្តកំពង់ធំ | ១០ | ០ | ១៣ | ០ | ១៦ | ០ |
| ខេត្តកោះកុង | ១ | ០ | ១០ | ០ | ៨ | ១ |
| ខេត្តពោធិ៍សាត់ | ៦ | ០ | ៨ | ០ | ១២ | ០ |
| ខេត្តបាត់ដំបង | ៤៣ | ០ | ៤៧ | ៤ | ៤៨ | ១ |
| ខេត្តបន្ទាយមានជ័យ | ៣២ | ៣ | ២៤ | ០ | ២០ | ០ |
| ខេត្តសៀមរាប | ០ | ០ | ៨៤ | ១ | ៧៣ | ១ |
| ខេត្តស្វាយរៀង | ១២ | ០ | ១៤ | ០ | ១៤ | ០ |
| **សរុប** | **៤៨២** | **០** | **៦០៨** | **១៤** | **៦៨៤** | **១៩** |

## លក្ខណៈពន្ធនាគារ

ស្ថានភាពជាក់ស្តែងរបស់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជា មានភាពខុសប្លែកគ្នាយ៉ាងខ្លាំង រវាងពន្ធនាគារដែលទើបជួសជុលថ្មី និងមានបរិក្ខាល្អ (ពន្ធនាគារតាខ្មៅ) និងពន្ធនាគារដ៏ចំណាស់ដែលមានអាយុកាលជិត ១០០ ឆ្នាំ និងមិនមានបន្ទប់សម្រាប់ឃុំឃាំងអ្នកទោសគ្រប់គ្រាន់ (ពន្ធនាគារខេត្តកំពង់ធំ) ប៉ុន្តែពន្ធនាគារទាំងអស់មានចំណុចដូចគ្នាមួយដែលមិនមានការផ្លាស់ប្តូរ គឺភាពចង្អៀត និងការដាក់អ្នកទោសលើសចំណុះ។ ភាពចង្អៀតនៅក្នុងពន្ធនាគាររបស់ប្រទេសកម្ពុជាក្នុងន័យសាមញ្ញមានន័យថា អ្នកទោសស្ត្រីត្រូវបានគេឃុំនៅជិតអ្នកទោសបុរស។ យោងតាមនីតិវិធីពន្ធនាគារលេខ ៣ អ្នកទោសស្ត្រីត្រូវឃុំឱ្យនៅដាច់ដោយឡែកពីអ្នកទោសបុរស។ ប៉ុន្តែ នីតិវិធីនេះមិនត្រូវបានអនុវត្តន៍ទូទៅទេ ដូចជា:

- នៅពន្ធនាគារទាំងនោះ: មណ្ឌលអប់រំកែប្រែទី២ (ម២) តាខ្មៅ ព្រះសីហនុ កំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ធំ កោះកុង ពោធិ៍សាត់ និងបន្ទាយមានជ័យ អ្នកទោសស្ត្រីត្រូវគេឃុំក្នុងអាគារឃុំឃាំងផ្សេងពីអ្នកទោសបុរស។
- ចំណែកនៅពន្ធនាគារបាត់ដំបង កំពង់ចាម និងស្វាយរៀង បន្ទប់ឃុំឃាំងរបស់អ្នកទោសស្ត្រីស្ថិតនៅជាប់ ឬក្បែរបន្ទប់ឃុំឃាំងរបស់អ្នកទោសបុរស។
- នៅពន្ធនាគារខេត្តសៀមរា បបន្ទប់ឃុំឃាំងរបស់ពិរុទ្ធជនបុរសស្ថិតនៅក្បែរបន្ទប់ឃុំឃាំងអ្នកទោសស្ត្រី ប៉ុន្តែបន្ទប់ឃុំឃាំងទណ្ឌិតបុរសនៅដាច់ដោយឡែកពីអ្នកទោសស្ត្រី។
- នៅពន្ធនាគារនគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) បន្ទប់ឃុំឃាំងរបស់អ្នកទោសបុរសស្ថិតនៅជាន់ទីមួយ និងបន្ទប់ឃុំឃាំងរបស់អ្នកទោសស្ត្រីស្ថិតនៅជាន់ទី២។
- ដោយឡែកនៅពន្ធនាគារមណ្ឌលអប់រំកែប្រែទី១ ត្រពាំងផ្លុង (ម៣) និងទួលស្លែង មិនមានអ្នកទោសស្ត្រីឡើយ។

ខាងក្រោមនេះ ជាសេចក្តីពិពណ៌នាសង្ខេបអំពីពន្ធនាគារដែលឃ្លាំមើលដោយអង្គការលីកាដូ :



- **ពន្ធនាគារខេត្តបាត់ដំបងៈ** ពន្ធនាគារខេត្តបាត់ដំបង បានផ្លាស់ប្តូរចេញពីទីតាំងចាស់ដែលស្ថិតនៅកណ្តាលទីរួមខេត្ត ទៅកាន់ទីតាំងថ្មីដែលស្ថិតនៅចំងាយប្រហែល ៥ គីឡូម៉ែត ពីទីរួមខេត្ត។ ពន្ធនាគារថ្មីនេះ សាងសង់រួចជាស្ថាពរនៅខែធ្នូ ឆ្នាំ២០០៥ ហើយអ្នកទោសត្រូវបានផ្ទេរទៅកាន់ ទីតាំងទីតាំងថ្មីនៅខែកុម្ភៈ ឆ្នាំ២០០៦។ នៅក្នុងឆ្នាំ២០០៧ លីកាដូ បានកត់ត្រាករណីរត់ចេញពីពន្ធនាគាររបស់អ្នកទោសជាបុរសម្នាក់ ប៉ុន្តែអ្នកទោសនោះ មិនត្រូវបានចាប់ខ្លួនវិញឡើយ។
- **ពន្ធនាគារខេត្តបន្ទាយមានជ័យៈ** នៅខែកុម្ភៈ ឆ្នាំ២០០៦ គម្រោងសាងសង់ពន្ធនាគារថ្មី ត្រូវបានគេគ្រោងឡើង ក្រោមកម្មវិធីដោះដូរដីមួយ ដែលធ្វើឡើងរវាងអាជ្ញាធរខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុនឯកជន។ តាមគម្រោង ពន្ធនាគារថ្មីនេះនឹងត្រូវសាងសង់រួចជាស្ថាពរនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៩ ហើយអ្នកទោសនឹងត្រូវផ្ទេរទៅកាន់ទីតាំងថ្មីភ្លាម បន្ទាប់ពន្ធនាគារសាងសង់រួចជាស្ថាពរ។ ពន្ធនាគារថ្មីនេះស្ថិតនៅចម្ងាយប្រហែល ១៤ គីឡូម៉ែត ខាងត្បូងឈៀងខាងលិចទីរួមខេត្តបន្ទាយមានជ័យ។



- **ពន្ធនាគារខេត្តកំពតៈ** ពន្ធនាគារនេះ ត្រូវបានកសាងនៅទសវត្សឆ្នាំ១៩៦០ ហើយមានទីតាំងស្ថិតនៅជិតស្នងការនគរបាលខេត្តកំពត។ ចន្លោះឆ្នាំ១៩៩៥ និងឆ្នាំ១៩៩៦ មានការជួសជុលកែលំអរអគារឃុំឃាំងអ្នកទោស និងសាងសង់អគារឃុំឃាំងអនីតិជនមួយ ក្រោមជំនួយឧបត្ថម្ភ របស់ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID)។



- **ពន្ធនាគារខេត្តកំពង់ចាមៈ** ពន្ធនាគារខេត្តកំពង់ចាមត្រូវបានផ្លាស់ប្តូរពីទីតាំងចាស់ ដែលស្ថិតនៅកណ្តាលទីរួមខេត្តកំពង់ចាម ទៅកាន់ទីតាំងថ្មី ដែលមានចម្ងាយប្រហែល ១០ គីឡូម៉ែត ពីទីរួមខេត្តនេះ។ នៅក្នុងឆ្នាំ២០០៨ លីកាដូ បានកត់ត្រាករណីរត់ចេញពីពន្ធនាគារចំនួនមួយករណី ហើយអ្នកទោសជាបុរសទាំងពីរនាក់ មិនត្រូវបានចាប់ខ្លួនវិញឡើយ។
- **ពន្ធនាគារខេត្តកំពង់ឆ្នាំងៈ** ពន្ធនាគារនេះស្ថិតនៅក្នុងទីរួមខេត្ត កំពង់ឆ្នាំង។ ពន្ធនាគារខេត្តកំពង់ឆ្នាំងត្រូវបានជួសជុល និងសាងសង់អគារបន្ថែមនៅក្នុងឆ្នាំ១៩៩៨ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារ

អូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(AusAID)។ អគារដែលត្រូវបានសាងសង់បន្ថែមមានរួមដូចជា អគារសម្រាប់ឃុំឃាំងអ្នកទោសទូទៅចំនួនពីរ អគារតូចសម្រាប់ឃុំឃាំងអនីតិជនចំនួនមួយ អគារតូចសម្រាប់ផ្ទះបាយចំនួន និងអគារពីរផ្សេងទៀត សម្រាប់អគាររដ្ឋបាល និងអគារស្នាក់នៅសម្រាប់មន្ត្រីពន្ធនាគារ។ បច្ចុប្បន្ន មានអគារចាស់តែមួយគត់ ដែលនៅបន្តប្រើប្រាស់សម្រាប់ឃុំឃាំងអ្នកទោស។ បើទោះជាមានការសាងសង់អគារបន្ថែមក៏ដោយ ក៏ចំនួនអ្នកទោសក្នុងពន្ធនាគារនេះ មានចំនួនលើសសមត្ថភាពផ្ទុករបស់វាយ៉ាង ច្រើន (២១៦ ភាគរយ)។



- **ពន្ធនាគារខេត្តកំពង់ស្ពឺ(រូបខាងឆ្វេង)៖** ពន្ធនាគារនេះត្រូវបានកសាងឡើងនៅទសវត្ស ឆ្នាំ១៩៨0 ហើយមានទីតាំងស្ថិតនៅជិតស្នងការនគរបាលខេត្ត។ ក្នុងឆ្នាំ១៩៩៦ មានការកសាងអគារឃុំឃាំងថ្មីចំនួនបីបន្ថែមទៀត ក្រោយជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID)។
- **ពន្ធនាគារខេត្តកំពង់ធំ៖** ជាពន្ធនាគារមួយចាស់ទ្រុឌទ្រោម ដែលយោងតាមការរាយការណ៍ថា បានកសាងឡើងតាំងពីទសវត្សឆ្នាំ១៩00មកម្ល៉េះ ហើយមានទីតាំងស្ថិតនៅក្នុងទីរួមខេត្តកំពង់ធំជិតសាលាខេត្តកំពង់ធំ។ ពន្ធនាគារមួយនេះ មានអគារសម្រាប់ឃុំឃាំងអ្នកទោសត្រឹមតែពីរអគារតែប៉ុណ្ណោះ។ អគារទី១ ដែលជាទូទៅត្រូវគេស្គាល់ថា បន្ទប់លេខ ៥ ត្រូវបានប្រើប្រាស់ ដើម្បីឃុំឃាំងអនីតិជន ពិរុទ្ធជន និងទណ្ឌិតជាបុរស ហើយអគារមួយទៀត សម្រាប់ឃុំឃាំងអ្នកទោសស្ត្រី។ អ្នកទោសនៅក្នុងពន្ធនាគារនេះ នាពេលបច្ចុប្បន្ន មានចំនួនលើសមត្ថភាពផ្ទុករបស់អគារយ៉ាងខ្លាំង (៣៥៣ ភាគរយ) ដែលមានន័យអ្នកទោសខ្លះត្រូវគេអនុញ្ញាតស្នាក់នៅ ក្រោមរោងប្រក់តង់ ពីព្រោះបន្ទប់លេខ ៥ ចង្អៀតពេក។ ក្នុងឆ្នាំ២00៨ មានករណីរួចរត់ចេញពីពន្ធនាគារដែលកើតឡើងនៅក្នុងពន្ធនាគារនេះចំនួន ៣ ករណី។ នៅក្នុងឆ្នាំ២00៨ លីកាដូ បានកត់ត្រាករណីរត់ចេញពីពន្ធនាគារ ចំនួន ៣ ករណី ផ្សេងគ្នា ។ ប៉ុន្តែមានតែអ្នកទោសម្នាក់ប៉ុណ្ណោះ ក្នុង ចំណោមអ្នកទោសជាបុរស ៥ នាក់ ត្រូវបានចាប់ខ្លួនមកវិញ។




- **ពន្ធនាគារខេត្តកោះកុង៖** ពន្ធនាគារនេះត្រូវបានផ្លាស់ប្តូរទីតាំងកាលពីខែឧសភាឆ្នាំ២00៦ ទៅកាន់ទីតាំងថ្មី ដែលស្ថិតនៅភាគខាងកើតទីរួមខេត្តកោះកុង ចំងាយប្រហែល ៦ គីឡូម៉ែត បន្ទាប់ពីទីតាំងចាស់ដែលស្ថិតនៅជិតសាលាខេត្ត បានលក់ឱ្យក្រុមហ៊ុនឯកជនដើម្បីធ្វើការអភិវឌ្ឍន៍។
- **ពន្ធនាគារខេត្តពោធិ៍សាត់៖** ពន្ធនាគារនេះកសាងឡើងនៅទសវត្សឆ្នាំ១៩៨0 ហើយមានទីតាំងស្ថិតនៅកណ្តាលទីរួមខេត្តពោធិ៍សាត់។ ចាប់តាំងពីសាងសង់រួមមក ពន្ធនាគារនេះមិនធ្លាប់ដែលជួលជុលអ្វីគួរកត់សម្គាល់នោះទេ។ អគារភាគច្រើនគ្រាន់តែ

មានការលាបថ្នាំសារជាថ្មីប៉ុណ្ណោះ។ នាពេលថ្មីៗនេះ មានការនិយាយតៗគ្នាថា ពន្ធនាគារថ្នាក់ជាតិថ្មីមួយទៀត (ពន្ធនាគារធំជាងគេបំផុត) នឹងត្រូវសាងសង់ឡើងនៅក្នុងខេត្តពោធិ៍សាត់ ប៉ុន្តែទោះជាយ៉ាងណា មិនទាន់មានការបញ្ជាក់ជាផ្លូវការណាមួយអំពីបញ្ហានេះនៅឡើយទេ។

- **ពន្ធនាគារខេត្តសៀមរាប:** នៅខែកុម្ភៈ ឆ្នាំ២០០៩ កម្មវិធីដោះដូរដីរវាងអាជ្ញាធរ និងក្រុម ហ៊ុនមួយ បានឃើញនូវការផ្លាស់ប្តូរទីតាំងពន្ធនាគារ ដើម្បីយកទីតាំងចាស់នោះ សាងសង់ផ្ទះល្វែង។ គេរំពឹងថា អ្នកទោសនឹងត្រូវផ្លាស់ប្តូរទៅកាន់ទីតាំងថ្មីនៅខែមេសា ឆ្នាំ២០០៩។ ពន្ធនាគារថ្មីនេះស្ថិតនៅចំងាយប្រហែល ១៤ គីឡូម៉ែត ពីសាលាខេត្តសៀមរាប។



- **ពន្ធនាគារខេត្តព្រះសីហនុ (រូបខាងឆ្វេង):** ចាប់តាំងពីកសាងតាំងឆ្នាំ១៩៨៦មក ពន្ធនាគារខេត្តព្រះសីហនុមិនធ្លាប់បានជួសជុលនោះទេ។ ប៉ុន្តែទោះជាយ៉ាងណា នៅខែវិច្ឆិកា ឆ្នាំ២០០៨ អគារសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានកសាងឡើង ក្រោមជំនួយឧបត្ថម្ភរបស់សាលាដុនបូស្កូ។ នៅក្នុងឆ្នាំ២០០៨ លីកាដូ បានកត់ត្រាករណីរត់ចេញពីពន្ធនាគាររបស់អ្នកទោសជាបុរសម្នាក់ ប៉ុន្តែអ្នកទោសនោះមិនត្រូវបានចាប់ខ្លួនវិញឡើយ។

- **ពន្ធនាគារខេត្តស្វាយរៀង:** ពន្ធនាគារនេះមានទីតាំងស្ថិតនៅ ជិតស្នងការនគរបាលខេត្ត ហើយមានអគារឃុំឃាំងត្រឹមតែពីរប៉ុណ្ណោះ។ អគារមួយដែលសាងសង់ឡើងពីឈើតាំងពីឆ្នាំ១៩៨៨ មកនោះ ត្រូវបានប្រើសម្រាប់ឃុំឃាំងអនីតិជន ពិរុទ្ធជន និងទណ្ឌិតជាបុរស ហើយអគារ មួយទៀតដែលសាងសង់ឡើងនៅឆ្នាំ២០០៣ ប្រើសម្រាប់ឃុំឃាំងអ្នកទោសស្ត្រី។ ក្នុងឆ្នាំ២០០៨ កាកបាទក្រហមអន្តរជាតិបានសាងសង់អគារមួយខ្នង សម្រាប់ធ្វើជាផ្ទះបាយ និងកន្លែងដាក់ឥវ៉ាន់។

- **ពន្ធនាគារនគរបាលយុត្តិធម៌ (ប៉េហ្ស៊ី ភ្នំពេញ):** ក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ ទីតាំងរបស់ពន្ធនាគារនគរបាលយុត្តិធម៌ ត្រូវបានលក់ទៅឱ្យក្រុមហ៊ុនឯកជនមួយ។ ពន្ធនាគារនេះ ត្រូវបានផ្លាស់ប្តូរទៅកាន់ទីតាំងថ្មីនៅខែសីហា ឆ្នាំ២០០៧ ដែលស្ថិតនៅជាយក្រុងភ្នំពេញ ក្នុងខណ្ឌឫស្សីកែវ ចំងាយប្រហែល ១៣ គីឡូម៉ែត ខាងជើងរាជធានីភ្នំពេញ។ ពន្ធនាគារថ្មីនេះស្ថិតនៅក្នុងបរិវេណស្នងការនគរបាលក្រុងភ្នំពេញ។

- **ពន្ធនាគារខេត្តកណ្តាល (តាខ្មៅ):** ពន្ធនាគារនេះត្រូវបានជួសជុលទាំងស្រុង ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារអូស្ត្រាលី សម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) ហើយត្រូវបានសម្ភោធជាផ្លូវការនៅខែ



វិច្ឆិកា ឆ្នាំ២០០៦។ ពន្ធនាគារនេះបានក្លាយជាពន្ធនាគារគំរូ ដោយសារមានអគារទំនើប ទាំងការរចនា និងគ្រោងបរិក្ខារ។ នៅក្នុងឆ្នាំ២០០៧ លីកាដូ បានកត់ត្រាករណីរត់ចេញពីពន្ធនាគារមួយករណី ហើយអ្នកទោសជាបុរសទាំង ៣ នាក់ ត្រូវបានចាប់ខ្លួនវិញ។

- **មណ្ឌលអប់រំកែប្រែទី១ (CC1):** ពន្ធនាគារនេះស្ថិតនៅខណ្ឌដង្កោ ចំងាយប្រហែល ១៥ គីឡូម៉ែត ខាងត្បូងឈាងខាងលិចរាជធានីភ្នំពេញ។ ពន្ធនាគារត្រូវបានគេស្គាល់ថា ជាពន្ធនាគារ ធំបំផុតនៅកម្ពុជា សម្រាប់ឃុំឃាំងអ្នកទោសជាបុរស ដោយមានចំនួនអ្នកទោសរហូតដល់ទៅ ២៥៥៨ នាក់។ ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) កំពុងឧបត្ថម្ភ ថវិកាមួយចំនួន តូច ដើម្បីធ្វើការកែលំអរផ្ទះបាយ និងបរិក្ខារសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- **មណ្ឌលអប់រំកែប្រែទី២ (CC2):** មណ្ឌលអប់រំកែប្រែទី២ ស្ថិតនៅជិតមណ្ឌលអប់រំកែប្រែទី១ (CC1) ហើយ ជាពន្ធនាគារតែមួយនៅប្រទេសកម្ពុជា ប្រើប្រាស់ដើម្បីឃុំឃាំងអ្នកទោសស្ត្រី និងអនីតិជន។ ចំនួនអ្នកទោសស្ត្រី និងអនីតិជននៅក្នុងពន្ធនាគារនេះ មានចំនួនច្រើនជាងពន្ធនាគារណាទាំងអស់នៅក្នុងប្រទេស (៦៥៩)។ នៅក្នុងឆ្នាំ២០០៨ លីកាដូ បានកត់ត្រាករណីរត់ចេញពីពន្ធនាគារចំនួន ១ ករណី។ មានតែអ្នកទោសម្នាក់ប៉ុណ្ណោះ ក្នុងចំណោមអ្នកទោសជាបុរស ២ នាក់ ត្រូវបានចាប់ខ្លួនវិញ ។



- **មណ្ឌលអប់រំកែប្រែទី៣ (CC3):** ពន្ធនាគារនេះស្ថិតនៅក្នុងស្រុកពញាក្រែក មានចំងាយប្រហែល ៧៥ គីឡូម៉ែត ខាងកើតទីរួមខេត្តកំពង់ចាម។ វាជាពន្ធនាគារដែលត្រូវបានប្រើប្រាស់ សម្រាប់តែឃុំឃាំងទណ្ឌិតជាបុរស (មិនមានពិរុទ្ធជនទេ)តែប៉ុណ្ណោះ។ ពន្ធនាគារនេះពុំធ្លាប់ដែលបានជួសជុលនោះទេ ចាប់តាំងពីសាងសង់ ហើយតាំងពីទសវត្សឆ្នាំ១៩៨០មកម្ល៉េះ។ ពន្ធនាគារក៏មាន កិត្តិនាមថាជាពន្ធនាគារដែលមានការរឹតបណ្តឹង ចំពោះការចូលសួរសុខទុក្ខអ្នកទោសផងដែរ។ បច្ចុប្បន្ន ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) កំពុងជួយឧបត្ថម្ភថវិកាសាងសង់មណ្ឌលសុខភាពថ្មី និងរបងការពារសន្តិសុខ។
- **អយ្យការយោធា (ពន្ធនាគារទួលស្លែង):** ពន្ធនាគារនេះជាពន្ធនាគារតែមួយគត់ដែរ ដែលត្រូវបានប្រើប្រាស់ សម្រាប់តែឃុំឃាំងអ្នកទោសផ្នែកយោធា។ បច្ចុប្បន្ននេះ មានអ្នកទោសផ្នែកយោធាពីរនាក់តែប៉ុណ្ណោះ កំពុងជាប់ឃុំឃាំងនៅក្នុងពន្ធនាគារនេះ។

□□□

# ៣. សុខភាពក្នុងពន្ធនាគារ

ខណៈបញ្ហាសុខភាពនៅក្នុងពន្ធនាគារភាគច្រើន ក៏កើតមានចំពោះប្រជាជនកម្ពុជាទូទៅដែរនោះ ស្ថានភាពបរិយាកាសនៅក្នុងពន្ធនាគារកាន់តែធ្វើបញ្ហាសុខភាពទាំងកាន់តែឧស្សាហ៍កើតមានឡើង ហើយធ្ងន់ធ្ងរទៀត។ ស្ថានភាពនៅក្នុងពន្ធនាគារដែលធ្វើឱ្យមានបញ្ហាសុខភាពកាន់តែធ្ងន់ធ្ងរថែមទៀតនោះ មានដូចជា ភាពចង្អៀត កង្វះសម្ភារៈស្អាត និងអណាម័យ ទឹកផឹកមិនស្អាត កង្វះអាហារ កង្វះខ្យល់អាកាសចេញចូលក្នុងបន្ទប់ ឃុំឃាំងការចេញមកខាងក្រៅមិនគ្រប់គ្រាន់ កង្វះការព្យាបាលសុខភាព និងអំពើទារុណកម្ម និងអំពើហិង្សា។

ប្រភេទជម្ងឺ ដែលអ្នកទោសកើត មានលក្ខណះខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ដោយ យោងទៅលើទំហំពន្ធនាគារ ចំនួនអ្នកទោស ទីតាំង និងបរិស្ថានរបស់ពន្ធនាគារ។ ក្នុងចំណោមពន្ធនាគារ ១៤[៧] ដែលឃ្លាំមើលដោយក្រុមពេទ្យនៃអង្គការលីកាដូ ប្រភេទជម្ងឺទូទៅដែលអ្នកទោសជួបប្រទះមានដូចជា:

- **ទួលស្លែង:** ជម្ងឺគ្រុនផ្តាសាយ និងបញ្ហាផ្លូវដង្ហើម
- **ប៉ៃហ្ស៊ី:** បញ្ហាផ្លូវដង្ហើម (រលាកទងសួត) ស្ពឹក (កង្វះវីតាមីន B1) ស្រេស និងឈឺក្រពះ
- **តាខ្មៅ:** រមាស់ ស្ពឹក គ្រុនផ្តាសាយ បញ្ហាផ្លូវដង្ហើម (រលាកទងសួត) រាគមួល
- **ព្រៃវែង:** ស្ពឹក រាគរូស បញ្ហាផ្លូវដង្ហើម គ្រុនផ្តាសាយ
- **ស្វាយរៀង:** ស្ពឹក រមាស់ រាគរូស រលាកប្លោកនោម របេង បញ្ហាផ្លូវដង្ហើម និងឈឺក្រពះ
- **តាកែវ:** ស្ពឹក រមាស់ បញ្ហាផ្លូវដង្ហើម បូស និងរាគរូស
- **ព្រះស៊ីហនុ:** រមាស់ ស្រែង ស្ពឹក រាគរូស បូស និងបញ្ហាផ្លូវដង្ហើម
- **កោះកុង:** រមាស់ ស្ពឹក របេង បូស បញ្ហាផ្លូវដង្ហើម និងរាគរូស
- **ពោធិ៍សាត់:** រមាស់ បូស បញ្ហាផ្លូវដង្ហើម ឈឺក្រពះ ស្រេស និងទឹកនោមផ្អែម
- **បាត់ដំបង:** ស្ពឹក រមាស់ បញ្ហាផ្លូវដង្ហើម ស្រេស និងរបេង
- **កំពង់ធំ:** រមាស់ បូស ស្ពឹក របេង និងគ្រុនចាញ់
- **មណ្ឌលអប់រំកែប្រែទី១ (ម១):** របេង រមាស់ ទឹកនោមផ្អែម បញ្ហាផ្លូវដង្ហើម និងកាមរោគ
- **មណ្ឌលអប់រំកែប្រែទី២ (ម២):** បូស រលាកភ្នែក បញ្ហាផ្លូវដង្ហើម រាគរូស និងឈឺក្រពះ

---

[៧] ក្រុមគ្រូពេទ្យបានចុះទៅពិនិត្យ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) និងមណ្ឌលអប់រំកែប្រែទី២ (ម ២) ប៉ុន្តែមិនបានទៅជាប្រចាំឡើយ។

ពន្ធនាគារដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរជាងគេមានៈ ពន្ធនាគារកំពង់ចាម កំពង់ធំ ព្រៃវែង ព្រះសីហនុ និងតាកែវ។ ពន្ធនាគារទាំងនេះ គឺស្ថិតនៅក្នុងចំណោមពន្ធនាគារដែលមានអ្នកទោសច្រើន និងមានបន្ទប់តូចចង្អៀត។ ចំណែកពន្ធនាគារកំពង់ធំ និងព្រៃវែងមិនមានទឹកម៉ាស៊ីនប្រើប្រាស់ឡើយ។



ពន្ធនាគារគេចាត់ទុកថាមានសេវាពេទ្យល្អគឺពន្ធនាគារនគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) និងតាខ្មៅ។ បើយើងប្រៀបធៀបពន្ធនាគារដែលអាក្រក់ជាងគេគឺ ពន្ធនាគារកំពង់ចាម ដោយសារតែអ្នកយាមពន្ធនាគារតឹងរឹង ហើយក្រុមគ្រូពេទ្យមិនអាចធ្វើការពិនិត្យដោយខ្លួនឯងបាន ទាល់តែអ្នកយាមពន្ធនាគារជាអ្នកជ្រើសរើសអ្នកទោស ឱ្យទទួលការព្យាបាល។ ម្យ៉ាងវិញទៀតពន្ធនាគារកំពង់ចាម បាត់ដំបង មណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី ២ ស្ថិតនៅឆ្ងាយពីមណ្ឌលសុខភាពពេក។

**ករណីសិក្សាៈ សុខភាពក្នុងពន្ធនាគារ**

នាងខ្ញុំឈ្មោះ គន្ធា អាយុ ៣០ ឆ្នាំ។ នាងខ្ញុំត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ៥ ឆ្នាំ ពីបទឆបោក។ ចាប់តាំងពីនាងខ្ញុំចូលមករស់នៅក្នុងពន្ធនាគារមក នាងខ្ញុំជួបបញ្ហាសុខភាពជាច្រើន។ រៀងរាល់ថ្ងៃ នាងខ្ញុំពុំមានទឹកស្អាត សម្រាប់ងូត និងបោកគក់សម្លៀកបំពាក់ទេ។ នាងខ្ញុំថែមទាំងមិនសំឡីអនាម័យសម្រាប់ប្រើប្រាស់ទៀតផង ហើយនាងខ្ញុំត្រូវប្រើប្រាស់ក្រណាត់ ឬក្រដាសកាសែតចាស់ៗ ជំនួសវិញ។ ដោយសារតែស្ថានភាពបែបនេះ នាងខ្ញុំបានជួបប្រទះបញ្ហាតំរង់នោម និងរោគស្ត្រី។ មន្ត្រីពន្ធនាគារថែមទាំងមិនអនុញ្ញាតឱ្យនាងខ្ញុំ ទៅទទួលការព្យាបាលនៅឯមន្ទីរពេទ្យ ឬគ្លីនិច។ ជម្រើសតែមួយគត់របស់នាងខ្ញុំគឺត្រូវរង់ចាំបុគ្គលិកពេទ្យរបស់អង្គការ ដែលមកផ្តល់ការត្រួវពិនិត្យសុខភាព និងឱសថដល់យើង។

## ការស្លាប់នៅក្នុងពន្ធនាគារ

ដោយសារសម្ភារៈប្រើប្រាស់ គ្រឿងបរិក្ខារ និងស្ថានភាពសុខភាពមិនល្អ ការស្លាប់ជារឿងអកោសល្យដែលកើតមានយ៉ាងពិតប្រាកដនៅក្នុងពន្ធនាគារ។ ការស្លាប់នៅក្នុងពន្ធនាគារភាគច្រើន បណ្តាលមកពីជំងឺ និងការឆ្លងមេរោគអេដស៍។

| ការស្លាប់នៅក្នុងមន្ទីរឃុំឃាំងក្នុងចំណោមពន្ធនាគារ១៨ ដែលឃ្លាំមើល ដោយអង្គការលីកាដូ ឆ្នាំ២០០៦-ឆ្នាំ២០០៨ | | | | | | |
|---|---|---|---|---|---|---|
| **ពន្ធនាគារ** | **២០០៦** | | **២០០៧** | | **២០០៨** | |
| | **បុរស** | **ស្ត្រី** | **បុរស** | **ស្ត្រី** | **បុរស** | **ស្ត្រី** |
| នគរបាលយុត្តិធម៌ (ប៉ៃហ្សិ) | 0 | 0 | 0 | 0 | 0 | 0 |
| មណ្ឌលអប់រំកែប្រែទី ១ (ម-១) | 0 | 0 | ១១ | 0 | ៦ | 0 |
| មណ្ឌលអប់រំកែប្រែទី ២ (ម-២) | 0 | ៤ | 0 | ៤ | 0 | 0 |
| មណ្ឌលអប់រំកែប្រែទី ៣ (ម-៣) | ២៤ | 0 | ១៥ | 0 | ៥ | 0 |
| ទួលស្លែង | ១ | 0 | 0 | 0 | 0 | 0 |
| តាខ្មៅ | ២ | 0 | ៣ | 0 | ៤ | 0 |
| ព្រះសីហនុ | ១ | 0 | 0 | 0 | 0 | 0 |
| កំពង់ស្ពឺ | ១ | 0 | 0 | 0 | ១ | 0 |
| កំពត | ៣ | 0 | ២ | 0 | ១ | 0 |
| កំពង់ឆ្នាំង | ១ | 0 | ៤ | 0 | ១ | 0 |
| កំពង់ចាម | ៩ | ១ | ៣ | 0 | ៦ | 0 |
| កំពង់ធំ | ១ | 0 | ១ | 0 | ២ | 0 |
| កោះកុង | ៤ | 0 | ១ | 0 | ៣ | 0 |
| ពោធិ៍សាត់ | ១ | 0 | ១ | 0 | 0 | 0 |
| បាត់ដំបង | ៩ | 0 | ៨ | 0 | ៣ | 0 |
| បន្ទាយមានជ័យ | ៣ | 0 | ២ | ១ | ៥ | 0 |
| សៀមរាប | ៤ | 0 | ១ | 0 | ១ | 0 |
| ស្វាយរៀង | 0 | 0 | 0 | 0 | ១ | 0 |
| **សរុប** | **៦៤** | **៥** | **៥២** | **៥** | **៣៩** | **0** |

## អំពើទារុណកម្មនៅក្នុងពន្ធនាគារ

ករណីប្រព្រឹត្តិទារុណកម្មទំនងជាមិនត្រូវបានរាយការឡើយ។ ការប្រមូលព័ត៌មានទាក់ទងនឹងអំពើទារុណកម្ម មានការលំបាកណាស់ពីព្រោះជនរងគ្រោះមួយចំនួនមិនហ៊ានរាយការទេ ដោយសារតែខ្លាចមានការវាយដំធ្វើឱ្យអាម៉ាស់ ឬ ការធ្វើបាបខាងផ្លូវចិត្តផ្សេងៗជាដើម។ ជាងនេះទៅទៀត អ្នកធ្វើទារុណ្ណកម្មបានប្រើបច្ចេកទេសពិសេសដែលមិនបន្សល់ស្លាកស្នាមដល់អ្នកសម្ភាសន៍មើលឃើញឡើយ ប៉ុន្តែ វាអាចបណ្តាលឱ្យមានរបួសផ្នែកខាងក្នុងរាងកាយយ៉ាងធ្ងន់ធ្ងរ។ កិច្ចសម្ភាសន៍ធ្វើឡើងរវាងអ្នកឃ្លាំមើល និងអ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ ជួនកាលធ្វើឡើងក្នុងខណៈពេលដែលមានឆ្មាំ និង អ្នកទោសដទៃទៀតមានវត្តមាននៅក្បែរនោះដែរ។

ខាងក្រោមនេះ គឺជាឌីយ៉ាក្រាមដែលបង្ហាញពីរបាយការណ៍នៃអំពើទារុណកម្មដែលធ្វើឡើងដោយក្រុមអ្នកសម្ភាសន៍របស់អង្គការលីកាដូក្នុងអំឡុងពេល ១០ ឆ្នាំកន្លង។

**របាយការណ៍ស្តីពីអំពើទារុណកម្មនៅក្នុងពន្ធនាគារ ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ១៩៩៩-២០០៨**




អំពើទារុណកម្មអាចកើតឡើងដោយស្រួលនៅក្នុងមន្ទីរឃុំឃាំងនគរបាល ពីព្រោះជនជាប់ចោទជាធម្មតាត្រូវឃុំឃាំងដោយពុំអាចទាក់ទងទៅខាងក្រៅរួមមាន ដូចជា គ្រួសារបងប្អូន បុគ្គលិកសិទ្ធិមនុស្ស មេធាវី ឬគ្រូពេទ្យ។ ប៉ុស្តិ៍នគរបាលត្រូវបិទជិតមិនឱ្យមានអ្នកក្រៅចូលបានទេ ដូច្នេះ គេអាចមានឱកាសល្មមគ្រាប់គ្រាន់

នឹងអាចធ្វើទារុណកម្មលើអ្នកទោសបានដោយគ្មានការត្រួតពិនិត្យ។ នគរបាលខ្មែរជាញឹកញាប់បានធ្វើទារុណកម្មលើជនសង្ស័យ ដើម្បីទទួលបានចំលើយសារភាព។ ទោះបីជាយ៉ាងណាក៏ដោយ ចំលើយដែលទទួលបានមិនអាចយកជាការបានឡើយ ចំលើយសារភាពមិនគួរអនុញ្ញាតិឱ្យយកទៅប្រើនៅក្នុងសវនាការតុលាការឡើយ ហើយជាលទ្ធផលនគរបាលដាក់ពន្ធនាគារជនសង្ស័យខុសទាំងប្រថុយប្រថាន។ ការចោទប្រកាន់លើអំពើទារុណកម្មនៅមន្ទីរឃុំឃាំងនគរបាលត្រូវបានប្រព្រឹត្តឡើងច្រើនជាងនៅក្នុងពន្ធនាគារ។

ប្រភេទអំពើទារុណកម្មដែលកើតមាននៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល ហើយដែលបានរាយការណ៍មកលីកាដូ មានដូចជា ការវាយជាមួយនឹងដំបងឈើ ដំបងឆក់ កាំភ្លើង ឧបករណ៍មិនមុតស្រួច និងទាត់ធាក់។ តារាងខាងក្រោមនេះ បង្ហាញនូវចំនួនករណីនៃការចោទប្រកាន់ពាក់ព័ន្ធនឹងអំពើទារុណកម្ម ដែលកើតមាននៅកន្លែងឃុំឃាំងរបស់នគរបាល ហើយដែលបានរាយការណ៍មកអ្នកស្រាវជ្រាវពន្ធនាគាររបស់លីកាដូ។

**របាយការណ៍អំពើទារុណកម្មនៅកន្លែងឃុំឃាំងនគរបាល ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ ២០០៦-២០០៨**

| ២០០៦ | | ២០០៧ | | ២០០៨ | |
|---|---|---|---|---|---|
| បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| ១៧៧ | ១៤ | ១១៨ | ៦ | ៧៧ | ១ |

**ករណីសិក្សា: ការធ្វើទារុណកម្ម និងការបៀតបៀនកេរ្តិ៍ខ្មាស់**

នាងខ្ញុំឈ្មោះ មាលា អាយុ ១៥ ឆ្នាំ។ នាងខ្ញុំជាអ្នកដើររើសអេតចាយ។ ក្នុងឆ្នាំ២០០៨ នគរបាលស្រុកបានចាប់ខ្លួន និងឃុំឃាំងនាងខ្ញុំអស់រយៈពេល ៥ ថ្ងៃ។ នគរបាលបានប្រាប់នាងខ្ញុំថា នាងខ្ញុំបានលួចលុយគេ។ នាងខ្ញុំពិតជាពុំយល់អំពីអ្វីដែលពួកគាត់កំពុងនិយាយនោះទេ ពីព្រោះពេលកើតហេតុនោះនាងខ្ញុំកំពុងនៅជាមួយមិត្តភក្តិរបស់នាងខ្ញុំ។ ពួកគាត់នៅតែបន្តនិយាយថា នាងខ្ញុំបានលួចលុយគេ ហើយនាងខ្ញុំត្រូវតែសារភាពអំពីទោសកំហុសរបស់ខ្លួន។ នាងខ្ញុំព្យាយាមពន្យល់ពួកគាត់ថា នាងខ្ញុំមិនបានលួចលុយគេនោះទេ ប៉ុន្តែពួកគាត់នៅតែមិនជឿខ្ញុំដដែល។

នគរបាលម្នាក់បានប្រើប្រាស់ដំបងវាយខ្ញុំចំនួន ៤ ដង ហើយបន្ទាប់មកយកបន្ទាត់វាយម៉ាត់របស់ខ្ញុំ។ នគរបាលម្នាក់ទៀតបានទះកំផ្លៀងនាងខ្ញុំពីរដង។ រាល់ពេលដែរពួកគាត់វាយនាងខ្ញុំ នាងខ្ញុំតែងតែស្រែកយ៉ាងខ្លាំងថា ខ្ញុំមិនបានធ្វើខុសនោះទេ។ បន្ទាប់មកទៀត ពួកគាត់បង្ខំឱ្យនាងខ្ញុំដោះសម្លៀកបំពាក់របស់នាងខ្ញុំ ប៉ុន្តែ នាងខ្ញុំមិនព្រម។ ទោះជាយ៉ាងណា ពួកគាត់បានចាប់ដោះសម្លៀកបំពាក់របស់នាងខ្ញុំ ហើយស្ទាបអង្អែល

ពេញខ្លួនប្រាណរបស់នាងខ្ញុំ។ នាងខ្ញុំមានអារម្មណ៍ថា អាម៉ាស់ខ្លាំងណាស់។ ទីបញ្ចប់ នាងខ្ញុំនៅតែត្រូវផ្តិតមេដៃលើក្រដាសមួយសន្លឹក ដោយសារភាពថា ខ្ញុំបានលុយគេ។



**ករណីសិក្សាៈ ការធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល**

នាងខ្ញុំឈ្មោះ វណ្ណថា អាយុ ២៩ ឆ្នាំ។ នាងខ្ញុំត្រូវបាននគរបាលចាប់ខ្លួន ដោយចោទប្រកាន់ពីបទមនុស្សឃាត។ នគរបាលបានចាប់ខ្លួននាងខ្ញុំនៅម៉ោងប្រហែលបួនកន្លះល្ងាច។ ពួកគេបានសួរសំនួរនាងខ្ញុំ ហើយបាននិយាយថា ខ្ញុំបានសម្លាប់ស្ត្រីម្នាក់។ ពួកគេប្រាប់នាងខ្ញុំអោយផ្តិតមេដៃនៅលើក្រដាសមួយសន្លឹក ដើម្បីសារភាពថា នាងខ្ញុំបានសម្លាប់មនុស្ស ប៉ុន្តែនាងខ្ញុំនៅតែបដិសេធ។ ពួកគេខឹងយ៉ាងខ្លាំង នៅពេលដែលខ្ញុំបដិសេធមិនព្រមសារភាព។ ពួកគេបានច្រានខ្ញុំផ្ទប់នឹងជញ្ជាំង ហើយវាយស្មាខ្ញុំនឹងកៅអី។ នាងខ្ញុំភ័យណាស់ ហើយមិនដឹងថានឹងត្រូវធ្វើយ៉ាងណា។ បន្តិចក្រោយមក ខ្ញុំមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងពេញរាងកាយ ហើយប្រដាប់ភេទរបស់ខ្ញុំចាប់ផ្តើមហូរឈាម។ បន្ទាប់មក នគរបាលបានបញ្ជូននាងខ្ញុំទៅកាន់មន្ទីរពេទ្យ ជាកន្លែងដែលគេប្រាប់នាងខ្ញុំថា នាងខ្ញុំរលូតកូន។ ខ្ញុំមានផ្ទៃពោះបីខែ។

ទាក់ទងនឹងការចោទប្រកាន់អំពីអំពើទារុណកម្មនៅក្នុងពន្ធនាគារវិញ ប្រភេទអំពើទារុណកម្មដែលឧស្សាហ៍កើតមានជាងគេ មានដូចជា ការដាក់ខ្នោះ ទាត់ធាក់ និងការបង្ខំឱ្យអ្នកទោសលីសែងរបស់ធ្ងន់រយៈពេលយូរ។ តារាងខាងក្រោម បង្ហាញនូវចំនួនករណីនៃការចោទប្រកាន់ពាក់ព័ន្ធនឹងអំពើទារុណកម្ម ដែលកើតមាននៅក្នុងពន្ធនាគារ ហើយដែលបាន រាយការណ៍មកអ្នកស្រាវជ្រាវពន្ធនាគាររបស់លីកាដូ។

| របាយការណ៍អំពើទារុណកម្មនៅក្នុងពន្ធនាគារ ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ២០០៦-២០០៨ | | | | | |
|---|---|---|---|---|---|
| ២០០៦ | | ២០០៧ | | ២០០៨ | |
| បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| ២២ | ០ | ២៦ | ៣ | ៧ | ០ |

អ្នកស្រាវជ្រាវពន្ធនាគាររបស់លីកាដូ ធ្វើការស្រាវជ្រាវរាល់ការចោទប្រកាន់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ដែលបានរាយការណ៍មកពួកគេ ហើយព្យាយាមអន្តរាគមន៍ ក្នុងតំណាងឱ្យអ្នកទោសរងគ្រោះ តាមលទ្ធភាពដែលពួកគេអាចធ្វើទៅបាន។ ការិយាល័យពេទ្យរបស់លីកាដូ ក៏ផ្តល់ជំនួយទៅតាមលទ្ធភាពរបស់ពួកគេផងដែរ។



□□□

# ៤. កុមារនៅក្នុងពន្ធនាគារ

ក្នុងខែមករា ឆ្នាំ២០០៩ មានកុមារចំនួន ៤០ នាក់ កំពុងរស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារ។ យោងតាមនីតិវិធីពន្ធនាគារលេខ ៣៤ កុមារក្រោមអាយុ ៦ ឆ្នាំ ត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយម្ដាយក្នុងពន្ធនាគារ ពេលដែរការធ្វើបែបនេះ វាផ្ដល់ឧត្តមប្រយោជន៍ដល់កុមារ។ ដោយសារដំណាក់ ៥ ឆ្នាំដំបូងរបស់កុមារ មានសារៈសំខាន់ចំពោះការលូតលាស់ខាងរាងកាយ សង្គម និងស្មារតី ដូចនេះនីតិវិធីពន្ធនាគារលេខ ៣៤ ក៏បានតម្រូវឱ្យអាជ្ញាធរពន្ធនាគារផ្ដល់ជូនកុមារនូវតម្រូវការជាមូលដ្ឋាននេះ។ ប៉ុន្តែជាជាក់ស្ដែង តម្រូវការជាចាំបាច់នេះត្រូវបានគេមិនយកមិត្តទុកដាក់ឡើយ។ ស្ត្រីជាម្ដាយ និងស្ត្រីមានផ្ទៃពោះមិនត្រូវបានផ្ដល់ជូននូវអាហារ ឬសម្ភារៈបន្ថែមសម្រាប់ថែទាំកូនរបស់ពួកគេនោះទេ។



កុមារដែលកំពុងរស់នៅក្នុងពន្ធនាគារជួបប្រទះនូវបញ្ហាកង្វះជីវជាតិ កង្វះនូវការផ្ដល់ជូនចំពោះតម្រូវការជាចំបាច់ និងកង្វះការអប់រំ ដែលមានសារៈសំខាន់ចំពោះការលូតលាស់របស់កុមារ។ ជាងនេះទៅទៀត កុមារត្រូវប្រឈមនឹងគ្រោះថ្នាក់លើរាងកាយ ដោយសារកុមារត្រូវបានគេដាក់ឱ្យរស់នៅជាមួយអ្នកទោស ដែលធ្លាប់បានប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយក៏ប្រឈមនឹងការធ្វើបាបដោយឆ្មាំពន្ធនាគារផងដែរ។

គម្រោងផ្ដល់ជំនួយម្ហូបអាហារដល់កុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគាររបស់លីកាដូ ចាប់ផ្ដើមឡើងក្នុងឆ្នាំ២០០៣ ដើម្បីប្រមែប្រមូល និងសម្របសម្រួលសម្ភារៈ និង ថវិកាជំនួយដល់កុមារ ម្ដាយរបស់កុមារ និងស្ត្រីមានផ្ទៃពោះរស់នៅក្នុងពន្ធនាគារ ។ ចាប់តាំងពីឆ្នាំ២០០៣មក លីកាដូបានជួយកុមារ និងឪពុកម្ដាយកុមារចំនួនជាង ១២០ នាក់ នូវជំនួយម្ហូបអាហារ សម្ភារៈ សេវាពេទ្យ និងសម្ភារៈជាទំនិញផ្សេងៗទៀតជាប្រចាំ។ ក្រោមការជួយជ្រោមជ្រែងពីអង្គការដៃគូ និងសប្បុរសជននានា ទាំងក្នុង និងក្រៅប្រទេស កុមារ និង ស្ត្រីទាំងនេះបានទទួលការជួយឧបត្ថម្ភយ៉ាងសមល្មម។ អ្នកទោសមួយចំនួនទទួលអំណោយរៀងរាល់ពីរសប្ដាហ៍ម្ដង ចំណែកឯអ្នកផ្សេងទៀត ទទួលបានអំណោយម្ដងក្នុងមួយខែ។

កុមាររស់នៅក្នុងពន្ធនាគារជាមួយឪពុកម្តាយពុំមែនជាអ្នកទោសទេ ហេតុនេះពួកគេមិនត្រូវទទួលទណ្ឌកម្មណាមួយឡើយ។ លីកាដូមានគោលបំណងធានាឱ្យកុមារគ្រប់គ្នាដែលរស់នៅក្នុងពន្ធនាគារមានអាហារ ទឹក កន្លែងរស់នៅល្អ ការព្យាបាល ការរៀនសូត្រ ឱកាសលេងកំសាន្ត និងការមានទំនាក់ទំនាក់ជាមួយសង្គមខាងក្រៅឱ្យបានសមរម្យ។

**ចំនួនស្ត្រីមានផ្ទៃពោះ និងកុមាររស់នៅជាមួយម្តាយនៅពន្ធនាគារខែមករា ឆ្នាំ២០០៩**

| ពន្ធនាគារ | ស្ត្រីមានផ្ទៃពោះ | កុមារ | |
|---|---|---|---|
| | | កុមារា | កុមារី |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ៤ | ១១ | ៦ |
| តាខ្មៅ | 0 | 0 | ២ |
| ខេត្តបាត់ដំបង | ១ | ១ | ២ |
| ខេត្តបន្ទាយមានជ័យ | 0 | ១ | ៣ |
| ខេត្តសៀមរាប | 0 | ៥ | ៣ |
| ព្រះសីហនុ | 0 | ១ | 0 |
| ខេត្តកោះកុង | 0 | ១ | 0 |
| កំពង់ឆ្នាំង | 0 | ២ | 0 |
| កំពង់ចាម | 0 | 0 | ២ |
| **សរុប** | **៥** | **២២** | **១៨** |

**ចំនួនកុមារដែលកើតក្នុងពន្ធនាគារ ឆ្នាំ២០០៧-២០០៨**

| ពន្ធនាគារ | ២០០៧ | | ២០០៨ | |
|---|---|---|---|---|
| | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី |
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | 0 | 0 | ១ | 0 |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ៣ | 0 | ២ | ២ |
| តាខ្មៅ | ២ | ១ | ១ | 0 |
| ខេត្តកំពង់ចាម | 0 | ១ | ១ | 0 |
| ខេត្តស្វាយរៀង | ១ | 0 | 0 | 0 |

| | | | | |
|---|---|---|---|---|
| ខេត្តសៀមរាប | ១ | ២ | ១ | 0 |
| ខេត្តកំពង់ធំ | ១ | 0 | ១ | 0 |
| ខេត្តពោធិ៍សាត់ | 0 | ១ | 0 | 0 |
| **សរុប** | **៨** | **៥** | **៧** | **២** |

□□□

# ៥. អនុសាសន៍

គោលដៅសំខាន់ក្នុងចាយផ្សាយរបាយការណ៍ គឺដើម្បីផ្តល់នូវព័ត៌មានមិនលំអៀង អំពីស្ថានភាពនៅក្នុងពន្ធនាគារ ជាវិស័យមួយងាយរងគ្រោះ និងមិនត្រូវគេឱ្យតម្លៃ និងជាក្រុមមួយដែលមិនមានមធ្យោបាយ ឬសម្លេងដើម្បីទាមទារឱ្យមានការផ្លាស់ប្តូរ និងភាពប្រសើរឡើងសម្រាប់ពួកគេ។ របាយការណ៍មានគោលបំណង ផ្តល់ឱ្យអ្នកអាននូវការពិត និងស្ថិតិមួយចំនួន ដែលលាតត្រដាងនូវស្ថានភាពរស់នៅក្នុងពន្ធនាគារ ក្នុងចំណោមពន្ធនាគារចំនួន ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ជាពិសេសពិពណ៌នាអំពីស្ថានភាពរបស់អ្នកទោសស្ត្រី។

ការវាយតម្លៃតែមួយគត់ ដែលយោងតាមស្ថិតិដែលមាននៅក្នុងរបាយការណ៍នេះគឺថា ស្ថានភាពពន្ធនាគារកាន់តែមិនល្អទៅៗ ប្រកបដោយក្តីសង្ឃឹមតិចសម្រាប់ការប្រសើរឡើង។ ភាពចង្អៀត ស្ថានភាពរស់នៅមិនល្អ និងបញ្ហាសុខភាព នឹងកាន់តែកើតមានច្រើនថែមទៀត។ ត្រឹមរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ ចំនួនអ្នកទោសដែលត្រូវបានឃ្លាំមើលដោយកម្មវិធីពន្ធនាគាររបស់អង្គការលីកាដូ បានកើតឡើង ៣២២ ភាគរយ។

ជាធម្មតា គេតែងនិយាយថា ប្រទេសមួយ ឬសង្គមមួយ គេអាចវាយតម្លៃបាន តាមរយៈទង្វើដែលពួកគេប្រព្រឹត្តចំពោះប្រជាជនដែលងាយរងគ្រោះរបស់ពួកគេ។

□□□

របាយការណ៍នេះបោះពុម្ពឡើងក្រោមជំនួយឧបត្ថម្ភពីសហគមន៍អឺរ៉ុប

http://www.licadho-cambodia.org/